# ព្រះ

# ត្រៃបិដកបាលី

# និង

# សេចក្តីប្រែជាភាសាខ្មែរ

# អភិធម្មបិដក

# បដ្ឋាន សោឡសមភាគ

# ១០៩



ផ្សព្វផ្សាយដោយសម្តេចព្រះអភិសិរីសុគន្ធាមហាសង្ឃរាជាធិបតី បួរ គ្រី
សម្តេចព្រះមហាសង្ឃរាជនៃគណៈធម្មយុត្តិកនិកាយ
នៃព្រះរាជាណាចក្រកម្ពុជា
*ព. ស. ២៥៥៣*

# ABHIDHAMMAPIṬAKA

## PAṬṬHĀNA

## SOḶASAMABHĀGA

# 109

សម្តេចព្រះអភិសិរីសុគន្ធាមហាសង្ឃរាជាធិបតី បួរ គ្រី
សម្តេចព្រះមហាសង្ឃរាជ នៃគណៈធម្មយុត្តិកនិកាយ នៃព្រះរាជាណាចក្រកម្ពុជា

# និយមវចនៈ

ព្រះត្រៃបិដកត្រូវបានបង្កើតឡើង ប្រមាណ៥០០ឆ្នាំប្លាយ ក្រោយអំពីការរំលត់ព្រះខន្ធចូលកាន់ ព្រះបរមនិព្វានរបស់សម្តេចព្រះសម្មាសម្ពុទ្ធព្រះបរមគ្រូជាអម្ចាស់នៃយើងគ្រប់គ្នា ។ គ្រប់ប្រទេស អ្នកកាន់ព្រះពុទ្ធសាសនា និងប្រទេសខ្លះមួយចំនួនមិនមែនអ្នកកាន់ព្រះពុទ្ធសាសនា គ្រប់អង្គការ ពុទ្ធិកសមាគម និងតាមបណ្ណាល័យជាតិធំ ៗ តែងតែបានទទួលយកមកតម្កល់ទុកធ្វើជាគ្រឹះ ដើម្បីធ្វើការស្រាវជ្រាវសិក្សាស្វែងយល់ តាមអ្វីដែលហៅថាព្រះពុទ្ធវាចា (ពុទ្ធធម៌) ។ កាលដើមឡើយគេនាំគ្នា កត់ត្រាលើស្លឹករឹត ព្រមទាំងសរសេរចារឹកលើផែនថ្ម និងលើផែនលោហៈក៏មាន លុះចំណេរតមក ក៏បាននាំគ្នាបោះពុម្ពលើក្រដាសចងក្រងជាសៀវភៅ (គម្ពីរ) រហូតបច្ចុប្បន្ននេះ បច្ចេកវិជ្ជាកាន់តែ ចម្រើនឡើង គេបានវាយបញ្ចូលក្នុងកុំព្យូទ័រ តែទោះបីជាបច្ចេកទេសម៉ាស៊ីនចម្រើនឡើងយ៉ាងណា ក៏នៅមិនអាចបោះបង់សៀវភៅចោលបានឡើយ ដូច្នេះហើយទើបយើងខ្ញុំបានខិតខំធ្វើឲ្យកើតមាន ឡើងនូវក្រុមអក្សរព្រះត្រៃបិដក ដើម្បីជួយធ្វើឲ្យអក្ខរៈខ្លះដែលរលុបមិនអាចអានច្បាស់បាន ឲ្យមាន ការច្បាស់តាមតួអក្ខរៈឡើងវិញ ។

ដោយសទ្ធាជ្រះថ្លាដ៏មុតមាំដែលមានចំពោះព្រះពុទ្ធសាសនា ហើយក៏ជាកាតព្វកិច្ចមួយដ៏ធំក្នុងតួនាទីជាពុទ្ធបរិស័ទ ដែលបានប្រគល់កាយថ្វាយជីវិត អ្នកធ្វើដំណើរតាមស្នាមព្រះបាទសម្តេចព្រះពុទ្ធអង្គ រួមកម្លាំងទ្រទ្រង់ បានធ្វើការលះបង់កម្លាំងកាយ វាចា ចិត្ត ទ្រព្យធនផ្ទាល់ ព្រមទាំងបបួលពុទ្ធបរិស័ទ ញាតិមិត្តជិតឆ្ងាយ ក្នុងនិងក្រៅប្រទេសធ្វើឡើង ដើម្បីជាពុទ្ធបូជា ធម្មបូជា សង្ឃបូជា ។

សូមសេចក្តីឧស្សាហ៍ក្នុងការជាកុសលនេះ សម្រេចប្រយោជន៍ជូនដល់ព្រះពុទ្ធសាសនាជូនដល់ពុទ្ធបរិស័ទ សូមបានប្រកបតែនឹងសេចក្តីសុខចម្រើនរុងរឿង ក្នុងលោកនេះផង និងលោកដទៃខាងមុខទៀតផង ជាភិយ្យោភាពតរៀងទៅ ។

វត្តបទុមឯ. ថ្ងៃទី ០៨ ខែមិថុនា ឆ្នាំ ២០០៩

បួរ-គ្រី

VATT Botum Dhammavutt Sangkat Chatumuk Khan Daun Penh P.Penh

Printed for free distribution by
**The Corporate Body of the Buddha Educational Foundation**
11F., 55 Hang Chow South Road Sec 1, Taipei, Taiwan, R.O.C.
Tel: 886-2-23951198 , Fax: 886-2-23913415
Email: overseas@budaedu.org
Website:http://www.budaedu.org
Mobile Web: m.budaedu.org
**This book is strictly for free distribution, it is not to be sold.**
សម្រាប់ចែកជាធម្មទាន

# សេចក្ដីណែនាំក្នុងការអាន

១) ប្រសិនបើលោកអ្នកអាន បានឃើញពាក្យទាំងឡាយណា ដែលមានសញ្ញាលេខបូកនៅពីខាងក្រោម ហើយបន្ទាប់មកបានឃើញព្យញ្ជនៈមួយតួទៀតនៅខាងចុងពាក្យនោះ សូមមេត្តាកត់សម្គាល់ថា ព្យញ្ជនៈដែលនៅខាងចុងនោះគឺជាជើងរបស់ព្យញ្ជនៈដែលមានសញ្ញាលេខបូកនៅពីខាងក្រោម ដោយកំហុសបច្ចេកទេសកុំព្យូទ័រ ។

**ឧទាហរណ៍**

-ពាក្យខ្មែរៈ **សម្ល** ក្នុងពាក្យនេះ ព្យញ្ជនៈ **ល** គឺជាជើងរបស់ព្យញ្ជនៈ **ម** ដូច្នេះពាក្យនេះគឺ **សម្ល** ។

-ពាក្យបាលីៈ **តស្ស** គឺ **តស្ស** ។

២) ចំពោះពាក្យខ្មែរ យើងសម្រេចយកតាមវចនានុក្រមខ្មែរ របស់សម្ដេចព្រះសង្ឃរាជជោតញ្ញាណោ (**ជួន-ណាត**) ជាគោល ។ ប៉ុន្តែបើពាក្យទាំងឡាយណា ដែលអាចសរសេរតាមបែបបុរាណក៏ត្រឹមត្រូវដែរនោះ យើងខ្ញុំសូមរក្សានូវពាក្យទាំងនោះទុកដដែល ។

៣) ចំពោះ **សង្កេតប្រាប់ពាក្យខុស-ត្រូវ** ដែលមាននៅផ្នែកខាងចុងនៃព្រះត្រៃបិដកច្បាប់ដើម ក្រុមយើងខ្ញុំសូមមិនដាក់ទៀតទេ ព្រោះក្រុមការងារយើងបានកែតម្រូវតាមនោះរួចរាល់ហើយ ។

# អភិធម្មបិដក

## បដ្ឋាន សោឡសមភាគ

១០៩

ព. ស. ២៥១២

# អភិធម្មបិដកេ

# បដ្ឋានស្ស សោឡសមោ ភាគោ

# អនុលោមប្បច្ចនីយប្បដ្ឋានំ

---

នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស ។

## អនុលោមប្បច្ចនីយត្តិកប្បដ្ឋានំ

## កុសលត្តិកេ នកុសលត្តិកំ

[១] កុសលំ ធម្មំ បដិច្ច នកុសលោ ធម្មោ ឧប្បជ្ជតិ ហេតុប្បច្ចយា កុសលេ ខន្ធេ បដិច្ច ចិត្តសមុដ្ឋានំ រូបំ ។ កុសលំ ធម្មំ បដិច្ច នអកុសលោ ធម្មោ ឧប្បជ្ជតិ ហេតុប្បច្ចយា កុសលំ ឯកំ ខន្ធំ បដិច្ច តយោ ខន្ធា ចិត្តសមុដ្ឋានញ្ច រូបំ ។ កុសលំ ធម្មំ បដិច្ច នអព្យាកតោ ធម្មោ ឧប្បជ្ជតិ ហេតុប្បច្ចយា កុសលំ ឯកំ ខន្ធំ បដិច្ច តយោ ខន្ធា ។ កុសលំ ធម្មំ បដិច្ច នអកុសលោ ច នអព្យាកតោ ច ធម្មា ឧប្បជ្ជន្តិ ហេតុប្បច្ចយា កុសលំ ឯកំ ខន្ធំ បដិច្ច តយោ ខន្ធា ។

# អភិធម្មបិដក

# បដ្ឋាន សោឡសមភាគ

# អនុលោមប្បច្ចនីយប្បដ្ឋាន

---

*សូមនមស្ការ ចំពោះព្រះមានព្រះភាគអរហន្តសម្មាសម្ពុទ្ធ អង្គនោះ ។*

## អនុលោមប្បច្ចនីយត្តិកប្បដ្ឋាន

## កុសលត្តិកៈ នកុសលត្តិកៈ

[១] *ធម៌ មិនមែនជាកុសល អាស្រ័យ នូវធម៌ ជាកុសល ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺ ចិត្តសមុដ្ឋានរូប អាស្រ័យ នូវពួកខន្ធ ជាកុសល ។ ធម៌ មិនមែន ជាអកុសល អាស្រ័យ នូវធម៌ ជាកុសល ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺ ខន្ធ ៣ ផង ចិត្តសមុដ្ឋានរូបផង អាស្រ័យ នូវខន្ធ ១ ជាកុសល ។ ធម៌ មិនមែនជាអព្យាកតៈ អាស្រ័យ នូវធម៌ ជាកុសល ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺ ខន្ធ ៣ អាស្រ័យ នូវខន្ធ ១ ជាកុសល ។ ធម៌ មិនមែនជាអកុសលក្តី មិនមែនជាអព្យាកតៈក្តី អាស្រ័យ នូវធម៌ ជាកុសល ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺ ខន្ធ ៣ អាស្រ័យ នូវខន្ធ ១ ជាកុសល ។*

កុសលំ ធម្មំ បដិច្ច នកុសលោ ច នអកុសលោ ច ធម្មា ឧប្បជ្ជន្តិ ហេតុប្បច្ចយា កុសលេ ខន្ធេ បដិច្ច ចិត្តសមុដ្ឋានំ រូបំ ។ បញ្ច ។

[២] អកុសលំ ធម្មំ បដិច្ច នអកុសលោ ធម្មោ ឧប្បជ្ជតិ ហេតុប្បច្ចយា អកុសលេ ខន្ធេ បដិច្ច ចិត្តសមុដ្ឋានំ រូបំ ។ អកុសលំ ធម្មំ បដិច្ច នកុស-លោ ធម្មោ ឧប្បជ្ជតិ ហេតុប្បច្ចយា អកុសលំ ឯកំ ខន្ធំ បដិច្ច តយោ ខន្ធា ចិត្តសមុដ្ឋានញ្ច រូបំ ។ អកុសលំ ធម្មំ បដិច្ច នអព្យាកតោ ធម្មោ ឧប្បជ្ជតិ ហេតុប្បច្ចយា អកុសលំ ធម្មំ បដិច្ច នកុសលោ ច នអព្យាកតោ ច ធម្មា ឧប្បជ្ជន្តិ ហេតុប្បច្ចយា អកុសលំ ធម្មំ បដិច្ច នកុសលោ ច នអកុស-លោ ច ធម្មា ឧប្បជ្ជន្តិ ហេតុប្បច្ចយា ។ បញ្ច ។

[៣] អព្យាកតំ ធម្មំ បដិច្ច នកុសលោ ធម្មោ ឧប្បជ្ជតិ ហេតុប្បច្ចយា វិបាកាព្យាកតំ កិរិយាព្យា-កតំ ឯកំ ខន្ធំ បដិច្ច តយោ ខន្ធា ចិត្តសមុដ្ឋា-នញ្ច រូបំ បដិសន្ធិ ឯកំ មហាភូតំ បដិច្ច តយោ មហាភូតា ទ្វេ មហាភូតេ បដិច្ច ទ្វេ មហាភូតា

ធម៌ មិនមែនជាកុសលក្តី មិនមែនជាអកុសលក្តី អាស្រ័យ នូវធម៌ ជាកុសល ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺ ចិត្តសមុដ្ឋានរូប អាស្រ័យ នូវពួកខន្ធ ជាកុសល ។ វារៈ ៥ ។

[២] ធម៌ មិនមែនជាអកុសល អាស្រ័យ នូវធម៌ ជាអកុសល ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺ ចិត្តសមុដ្ឋានរូប អាស្រ័យ នូវពួកខន្ធ ជាអកុសល ។ ធម៌ មិនមែនជាកុសល អាស្រ័យ នូវធម៌ ជាអកុសល ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺ ខន្ធ ៣ ផង ចិត្ត-សមុដ្ឋានរូបផង អាស្រ័យ នូវខន្ធ ១ ជាអកុសល ។ ធម៌ មិនមែនជាអព្យាកតៈ អាស្រ័យ នូវធម៌ ជាអកុសល ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ធម៌ មិនមែនជាកុសលក្តី មិនមែនជាអព្យាកតៈក្តី អាស្រ័យ នូវធម៌ ជាអកុសល ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ធម៌ មិនមែនជាកុសលក្តី មិនមែនជាអកុសលក្តី អាស្រ័យ នូវធម៌ ជាអកុសល ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។ វារៈ ៥ ។

[៣] ធម៌ មិនមែនជាកុសល អាស្រ័យ នូវធម៌ ជាអព្យាកតៈ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺ ខន្ធ ៣ ផង ចិត្តសមុដ្ឋានរូបផង ជាបដិសន្ធិ អាស្រ័យ នូវខន្ធ ១ ជាវិបាកាព្យាកតៈ និងជាកិរិយាព្យាកតៈ មហាភូត ៣ អាស្រ័យ នូវមហាភូត ១ មហាភូត ២ អាស្រ័យ នូវមហាភូត ២

មហាភូតេ បដិច្ច ចិត្តសមុដ្ឋានំ រូបំ ។ អព្យាកតំ ធម្មំ បដិច្ច នអកុសលោ ធម្មោ ឧប្បជ្ជតិ ហេតុប្បច្ចយា វិបាកាព្យាកតំ បដិសន្ធិ មហាភូតំ ។ អព្យាកតំ ធម្មំ បដិច្ច នកុសលោ ច នអកុសលោ ច ធម្មា ឧប្បជ្ជន្តិ ហេតុប្បច្ចយា វិបាកាព្យាកតំ កិរិយាព្យាកតំ ។ សង្ខិត្តំ ។ តីណិ ។

[៤] កុសលញ្ច អព្យាកតញ្ច ធម្មំ បដិច្ច នកុសលោ ធម្មោ ឧប្បជ្ជតិ ហេតុប្បច្ចយា កុសលេ ខន្ធេ ច មហាភូតេ ច បដិច្ច ចិត្តសមុដ្ឋានំ រូបំ ។ កុសលញ្ច អព្យាកតញ្ច ធម្មំ បដិច្ច នអកុសលោ ធម្មោ ឧប្បជ្ជតិ ហេតុប្បច្ចយា កុសលញ្ច អព្យាកតញ្ច ធម្មំ បដិច្ច នកុសលោ ច នអកុសលោ ច ធម្មា ឧប្បជ្ជន្តិ ហេតុប្បច្ចយា ។

[៥] អកុសលញ្ច អព្យាកតញ្ច ធម្មំ បដិច្ច នកុសលោ ធម្មោ ឧប្បជ្ជតិ ហេតុប្បច្ចយា អកុសលញ្ច អព្យាកតញ្ច ធម្មំ បដិច្ច នអកុសលោ ធម្មោ ឧប្បជ្ជតិ ហេតុប្បច្ចយា អកុសលញ្ច អព្យាកតញ្ច ធម្មំ បដិច្ច នកុសលោ ច នអកុសលោ ច ធម្មា

ចិត្តសមុដ្ឋានរូប អាស្រ័យ នូវពួកមហាភូត ។ ធម៌ មិនមែនជាអកុសល អាស្រ័យ នូវធម៌ ជាអព្យាកតៈ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺ វិបាកាព្យាកតបដិសន្ធិ និងមហាភូត ។ ធម៌ មិនមែនជាកុសលក្តី មិនមែនជាអកុសលក្តី អាស្រ័យ នូវធម៌ ជាអព្យាកតៈ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺ វិបាកាព្យាកតៈ និងកិរិយាព្យាកតៈ ។ សេចក្តីបំប្រួញ ។ វារៈ ៣ ។

[៤] ធម៌ មិនមែនជាកុសល អាស្រ័យ នូវធម៌ ជាកុសលផង ជាអព្យាកតៈផង ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺ ចិត្តសមុដ្ឋានរូប អាស្រ័យ នូវពួកខន្ធ ជាកុសលផង នូវពួកមហាភូតផង ។ ធម៌ មិនមែនជាអកុសល អាស្រ័យ នូវធម៌ ជាកុសលផង ជាអព្យាកតៈផង ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ធម៌ មិនមែនជាកុសលក្តី មិនមែនជាអកុសលក្តី អាស្រ័យ នូវធម៌ ជាកុសលផង ជាអព្យាកតៈផង ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។

[៥] ធម៌ មិនមែនជាកុសល អាស្រ័យ នូវធម៌ ជាអកុសលផង ជាអព្យាកតៈផង ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ធម៌ មិនមែនជាអកុសល អាស្រ័យ នូវធម៌ ជាអកុសលផង ជាអព្យាកតៈផង ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ធម៌ មិនមែនជាកុសលក្តី មិនមែនជាអកុសលក្តី អាស្រ័យ នូវធម៌ ជាអកុសលផង ជាអព្យាកតៈផង

ឧប្បជ្ជន្តិ ហេតុប្បច្ចយា ចិត្តសមុដ្ឋានរូបមេវ ឯត្ថ វត្តតិ ។

ឯកូនវីសតិ បញ្ហា កាតព្វា ។

[៦] កុសលំ ធម្មំ បដិច្ច នអកុសលោ ធម្មោ ឧប្បជ្ជតិ អារម្មណប្បច្ចយា កុសលំ ធម្មំ បដិច្ច ន-អព្យាកតោ ធម្មោ ឧប្បជ្ជតិ អារម្មណប្បច្ចយា កុ-សលំ ធម្មំ បដិច្ច នអកុសលោ ច នអព្យាកតោ ច ធម្មា ឧប្បជ្ជន្តិ អារម្មណប្បច្ចយា តីណិ ។

[៧] អកុសលំ ធម្មំ បដិច្ច នកុសលោ ធម្មោ ឧប្បជ្ជតិ អារម្មណប្បច្ចយា អកុសលំ ធម្មំ បដិច្ច នអព្យាកតោ ធម្មោ ឧប្បជ្ជតិ អារម្មណប្បច្ចយា អកុសលំ ធម្មំ បដិច្ច នកុសលោ ច នអព្យាកតោ ច ធម្មា ឧប្បជ្ជន្តិ អារម្មណប្បច្ចយា តីណិ ។

[៨] អព្យាកតំ ធម្មំ បដិច្ច នកុសលោ ធម្មោ ឧប្បជ្ជតិ អារម្មណប្បច្ចយា អព្យាកតំ ធម្មំ បដិច្ច ន-អកុសលោ ធម្មោ ឧប្បជ្ជតិ អារម្មណប្បច្ចយា អព្យា-កតំ ធម្មំ បដិច្ច នកុសលោ ច នអកុសលោ ច ធម្មា ឧប្បជ្ជន្តិ អារម្មណប្បច្ចយា តីណិ ។

ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺ ចិត្តសមុដ្ឋានរូបតែម្យ៉ាង ប្រព្រឹត្តទៅ ក្នុងតិកៈនេះ ។

បញ្ហា ១៩ បណ្ឌិត គប្បីធ្វើផងចុះ ។

[៦] ធម៌ មិនមែនជាអកុសល អាស្រ័យ នូវធម៌ ជាកុសល ទើបកើតឡើង ព្រោះអារម្មណប្បច្ច័យ ធម៌ មិនមែនជាអព្យាកតៈ អាស្រ័យ នូវធម៌ ជាកុសល ទើបកើតឡើង ព្រោះអារម្មណប្បច្ច័យ ធម៌ មិនមែនជាអកុសលក្តី មិនមែនជាអព្យាកតៈក្តី អាស្រ័យ នូវធម៌ ជាកុសល ទើបកើតឡើង ព្រោះអារម្មណប្បច្ច័យ មានវារៈ ៣ ។

[៧] ធម៌ មិនមែនជាកុសល អាស្រ័យ នូវធម៌ ជាអកុសល ទើបកើតឡើង ព្រោះអារម្មណប្បច្ច័យ ធម៌ មិនមែនជាអព្យាកតៈ អាស្រ័យ នូវធម៌ ជាអកុសល ទើបកើតឡើង ព្រោះអារម្មណប្បច្ច័យ ធម៌ មិនមែនជាកុសលក្តី មិនមែនជាអព្យាកតៈក្តី អាស្រ័យ នូវធម៌ ជាអកុសល ទើបកើតឡើង ព្រោះអារម្មណប្បច្ច័យ មានវារៈ ៣ ។

[៨] ធម៌ មិនមែនជាកុសល អាស្រ័យ នូវធម៌ ជាអព្យាកតៈ ទើបកើតឡើង ព្រោះអារម្មណប្បច្ច័យ ធម៌ មិនមែនជាអកុសល អាស្រ័យ នូវធម៌ ជាអព្យាកតៈ ទើបកើតឡើង ព្រោះអារម្មណប្បច្ច័យ ធម៌ មិនមែនជាកុសលក្តី មិនមែនជាអកុសលក្តី អាស្រ័យ នូវធម៌ ជាអព្យាកតៈ ទើបកើតឡើង ព្រោះអារម្មណប្បច្ច័យ មានវារៈ ៣ ។

អនុលោមបច្ចនីយត្តិកបដ្ឋានំ

[៩] ហេតុយា ឯកូនវីស អារម្មណេ នវ អធិ-
បតិយា ឯកូនវីស អនន្តរេ នវ សមនន្តរេ នវ សហ-
ជាតេ ឯកូនវីស អវិគតេ ឯកូនវីស ។

[១០] អកុសលំ ធម្មំ បដិច្ច នកុសលោ ធម្មោ
ឧប្បជ្ជតិ នហេតុប្បច្ចយា អកុសលំ ធម្មំ បដិច្ច ន-
អព្យាកតោ ធម្មោ ឧប្បជ្ជតិ នហេតុប្បច្ចយា អកុ-
សលំ ធម្មំ បដិច្ច នកុសលោ ច នអព្យាកតោ
ច ធម្មា ឧប្បជ្ជន្តិ នហេតុប្បច្ចយា តីណិ ។ អព្យា-
កតំ ធម្មំ បដិច្ច នកុសលោ ធម្មោ ឧប្បជ្ជតិ ន-
ហេតុប្បច្ចយា អព្យាកតំ ធម្មំ បដិច្ច នអកុសលោ
ធម្មោ ឧប្បជ្ជតិ នហេតុប្បច្ចយា អព្យាកតំ ធម្មំ
បដិច្ច នកុសលោ ច នអកុសលោ ច ធម្មា
ឧប្បជ្ជន្តិ នហេតុប្បច្ចយា តីណិ ។

[១១] កុសលំ ធម្មំ បដិច្ច នកុសលោ ធម្មោ
ឧប្បជ្ជតិ នអារម្មណប្បច្ចយា កុសលំ ធម្មំ បដិច្ច
នអកុសលោ ធម្មោ ឧប្បជ្ជតិ នអារម្មណប្បច្ចយា
កុសលំ ធម្មំ បដិច្ច នកុសលោ ច នអកុស-
លោ ច ធម្មា ឧប្បជ្ជន្តិ នអារម្មណប្បច្ចយា ។

អនុលោមប្បច្ចនីយត្តិកប្បដ្ឋាន

[៩] ក្នុងហេតុប្បច្ច័យ មានវារៈ ១៩ ក្នុងអារម្មណប្បច្ច័យ មានវារៈ ៩ ក្នុងអធិបតិប្បច្ច័យ មានវារៈ ១៩ ក្នុងអនន្តរប្បច្ច័យ មានវារៈ ៩ ក្នុងសមនន្តរប្បច្ច័យ មានវារៈ ៩ ក្នុងសហជាតប្បច្ច័យ មានវារៈ ១៩ ក្នុងអវិគតប្បច្ច័យ មានវារៈ ១៩ ។

[១០] ធម៌ មិនមែនជាកុសល អាស្រ័យ នូវធម៌ ជាអកុសល ទើបកើតឡើង ព្រោះនហេតុប្បច្ច័យ ធម៌ មិនមែនជាអព្យាកតៈ អាស្រ័យ នូវធម៌ ជាអកុសល ទើបកើតឡើង ព្រោះនហេតុប្បច្ច័យ ធម៌ មិនមែនជាកុសលក្តី មិនមែនជាអព្យាកតៈក្តី អាស្រ័យ នូវធម៌ ជាអកុសល ទើបកើតឡើង ព្រោះនហេតុប្បច្ច័យ មានវារៈ ៣ ។ ធម៌ មិនមែនជាកុសល អាស្រ័យ នូវធម៌ ជាអព្យាកតៈ ទើបកើតឡើង ព្រោះនហេតុប្បច្ច័យ ធម៌ មិនមែនជាអកុសល អាស្រ័យ នូវធម៌ ជាអព្យាកតៈ ទើបកើតឡើង ព្រោះនហេតុប្បច្ច័យ ធម៌ មិនមែនជាកុសលក្តី មិនមែនជាអកុសលក្តី អាស្រ័យ នូវធម៌ ជាអព្យាកតៈ ទើបកើតឡើង ព្រោះនហេតុប្បច្ច័យ មានវារៈ ៣ ។

[១១] ធម៌ មិនមែនជាកុសល អាស្រ័យ នូវធម៌ ជាកុសល ទើបកើតឡើង ព្រោះនអារម្មណប្បច្ច័យ ធម៌ មិនមែនជាអកុសល អាស្រ័យ នូវធម៌ ជាកុសល ទើបកើតឡើង ព្រោះនអារម្មណប្បច្ច័យ ធម៌ មិនមែនជាកុសលក្តី មិនមែនជាអកុសលក្តី អាស្រ័យ នូវធម៌ ជាកុសល ទើបកើតឡើង ព្រោះនអារម្មណប្បច្ច័យ ។

អកុសលំ ធម្មំ បដិច្ច នអកុសលោ ធម្មោ ឧប្ប-ជ្ជតិ នអារម្មណប្បច្ចយា អកុសលំ ធម្មំ បដិច្ច ន-កុសលោ ធម្មោ ឧប្បជ្ជតិ នអារម្មណប្បច្ចយា អកុ-សលំ ធម្មំ បដិច្ច នកុសលោ ច នអកុសលោ ច ធម្មា ឧប្បជ្ជន្តិ នអារម្មណប្បច្ចយា ។

[១២] នហេតុយា ធ នអារម្មណេ បណ្ណរស នអធិបតិយា ឯកូនវីស នោវិកតេ បណ្ណរស ។

បច្ចនីយំ វិត្ថារេតព្វំ សហជាតវារម្បិ វិត្ថារេតព្វំ បច្ចយវារម្បិ វិត្ថារេតព្វំ ។

[១៣] បច្ចយវារេបិ ហេតុយា ធព្វីស អារម្ម-ណេ អដ្ឋារស អវិគតេ ធព្វីស ។

និស្សយវារម្បិ សំសដ្ឋវារម្បិ សម្បយុត្តវារម្បិ បដិច្ចវារសទិសំ ។

[១៤] កុសលោ ធម្មោ នកុសលស្ស ធម្មស្ស ហេតុប្បច្ចយេន បច្ចយោ កុសលោ ធម្មោ នអ-ព្យាកតស្ស ធម្មស្ស ហេតុប្បច្ចយេន បច្ចយោ កុ-សលោ ធម្មោ នកុសលស្ស ច នអព្យាកតស្ស ច ធម្មស្ស ហេតុប្បច្ចយេន បច្ចយោ កុសលោ ធម្មោ នកុសលស្ស ច នអកុសលស្ស ច ធម្មស្ស ហេតុប្បច្ចយេន បច្ចយោ បញ្ច ។

ធម៌ មិនមែនជាអកុសល អាស្រ័យ នូវធម៌ ជាអកុសល ទើបកើតឡើង ព្រោះនអារម្មណប្បច្ច័យ ធម៌ មិនមែនជាកុសល អាស្រ័យ នូវធម៌ ជាអកុសល ទើបកើតឡើង ព្រោះនអារម្មណប្បច្ច័យ ធម៌ មិនមែនជាកុសលក្តី ធម៌ មិនមែនជាអកុសលក្តី អាស្រ័យ នូវធម៌ ជាអកុសល ទើបកើតឡើង ព្រោះនអារម្មណប្បច្ច័យ ។

[១២] ក្នុងនហេតុប្បច្ច័យ មានវារៈ ៦ ក្នុងនអារម្មណប្បច្ច័យ មានវារៈ ១៥ ក្នុងនអធិបតិប្បច្ច័យ មានវារៈ ១៩ ក្នុងនោវិគតប្បច្ច័យ មានវារៈ ១៥ ។

បច្ចនីយៈ បណ្ឌិត គប្បីឲ្យពិស្តារ ទាំងសហជាតវារៈក្តី បណ្ឌិត គប្បីឲ្យពិស្តារ ទាំងបច្ចយវារៈក្តី បណ្ឌិត ក៏គប្បីឲ្យពិស្តារ ។

[១៣] ចំណែកខាងបច្ចយវារៈ ក្នុងហេតុប្បច្ច័យ មានវារៈ ២៦ ក្នុងអារម្មណប្បច្ច័យ មានវារៈ ១៨ ក្នុងអវិគតប្បច្ច័យ មានវារៈ ២៦ ។

និស្សយវារៈក្តី សំសដ្ឋវារៈក្តី សម្បយុត្តវារៈក្តី ប្រហែលគ្នានឹងបដិច្ចវារៈដែរ ។

[១៤] ធម៌ ជាកុសល ជាបច្ច័យ នៃធម៌ មិនមែនជាកុសល ដោយហេតុប្បច្ច័យ ធម៌ ជាកុសល ជាបច្ច័យ នៃធម៌ មិនមែនជាអព្យាកតៈ ដោយហេតុប្បច្ច័យ ធម៌ ជាកុសល ជាបច្ច័យ នៃធម៌ មិនមែនជាកុសលផង មិនមែនជាអព្យាកតៈផង ដោយហេតុប្បច្ច័យ ធម៌ ជាកុសល ជាបច្ច័យ នៃធម៌ មិនមែនជាកុសលផង មិនមែនជាអកុសលផង ដោយហេតុប្បច្ច័យ មានវារៈ ៥ ។

៧

## អនុលោមប្បច្ចនីយត្តិកប្បដ្ឋានំ

[១៥] អកុសលោ ធម្មោ នអកុសលស្ស ធម្មស្ស ហេតុប្បច្ចយេន បច្ចយោ អកុសលោ ធម្មោ នកុសលស្ស ធម្មស្ស ហេតុប្បច្ចយេន បច្ចយោ អកុសលោ ធម្មោ នអព្យាកតស្ស ធម្មស្ស ហេតុប្បច្ចយេន បច្ចយោ អកុសលោ ធម្មោ នអកុសលស្ស ច នអព្យាកតស្ស ច ធម្មស្ស ហេតុប្បច្ចយេន បច្ចយោ អកុសលោ ធម្មោ នកុសលស្ស ច នអកុសលស្ស ច ធម្មស្ស ហេតុប្បច្ចយេន បច្ចយោ បញ្ច ។

[១៦] អព្យាកតោ ធម្មោ នកុសលស្ស ធម្មស្ស ហេតុប្បច្ចយេន បច្ចយោ អព្យាកតោ ធម្មោ នអកុសលស្ស ធម្មស្ស ហេតុប្បច្ចយេន បច្ចយោ អព្យាកតោ ធម្មោ នកុសលស្ស ច នអកុសលស្ស ច ធម្មស្ស ហេតុប្បច្ចយេន បច្ចយោ តីណិ ។

[១៧] កុសលោ ធម្មោ នកុសលស្ស ធម្មស្ស អារម្មណប្បច្ចយេន បច្ចយោ ឆ ។ អកុសលោ ធម្មោ នអកុសលស្ស ធម្មស្ស អារម្មណប្បច្ចយេន បច្ចយោ ឆ ។ អព្យាកតោ ធម្មោ នអព្យាកតស្ស ធម្មស្ស អារម្មណប្បច្ចយេន បច្ចយោ ឆ ។

អនុលោមប្បច្ចនីយត្តិកប្បដ្ឋាន

[១៥] ធម៌ ជាអកុសល ជាបច្ច័យ នៃធម៌ មិនមែនជាអកុសល ដោយហេតុប្បច្ច័យ ធម៌ ជាអកុសល ជាបច្ច័យ នៃធម៌ មិនមែនជាកុសល ដោយហេតុប្បច្ច័យ ធម៌ ជាអកុសល ជាបច្ច័យ នៃធម៌ មិនមែនជាអព្យាកតៈ ដោយហេតុប្បច្ច័យ ធម៌ ជាអកុសល ជាបច្ច័យ នៃធម៌ មិនមែនជាអកុសលផង មិនមែនជាអព្យាកតៈផង ដោយហេតុប្បច្ច័យ ធម៌ ជាអកុសល ជាបច្ច័យ នៃធម៌ មិនមែនជាកុសលផង មិនមែនជាអកុសលផង ដោយហេតុប្បច្ច័យ មានវារៈ ៥ ។

[១៦] ធម៌ ជាអព្យាកតៈ ជាបច្ច័យ នៃធម៌ មិនមែនជាកុសល ដោយហេតុប្បច្ច័យ ធម៌ ជាអព្យាកតៈ ជាបច្ច័យ នៃធម៌ មិនមែនជាអកុសល ដោយហេតុប្បច្ច័យ ធម៌ ជាអព្យាកតៈ ជាបច្ច័យ នៃធម៌ មិនមែនជាកុសលផង មិនមែនជាអកុសលផង ដោយហេតុប្បច្ច័យ មានវារៈ ៣ ។

[១៧] ធម៌ ជាកុសល ជាបច្ច័យ នៃធម៌ មិនមែនជាកុសល ដោយអារម្មណប្បច្ច័យ មានវារៈ ៦ ។ ធម៌ ជាអកុសល ជាបច្ច័យ នៃធម៌ មិនមែនជាអកុសល ដោយអារម្មណប្បច្ច័យ មានវារៈ ៦ ។ ធម៌ ជាអព្យាកតៈ ជាបច្ច័យ នៃធម៌ មិនមែនជាអព្យាកតៈ ដោយអារម្មណប្បច្ច័យ មានវារៈ ៦ ។

[១៨] ហេតុយា តេវស អារម្មណេ អដ្ឋារស អធិបតិយា សត្តរស អនន្តរេ សោឡស សមនន្តរេ សោឡស សហជាតេ ឯកូនវីស អញ្ញមញ្ញេ នវ និស្សយេ ឆព្វីស ឧបនិស្សយេ អដ្ឋារស បុរេជាតេ ច បច្ឆាជាតេ នវ កម្មេ តេវស វិបាកេ តីណិ អាហារេ តេវស ។ បេ ។ មគ្គេ តេវស សម្បយុត្តេ នវ វិប្បយុត្តេ ទ្វាទស ។ បេ ។ អវិគតេ ឆព្វីស ។

បញ្ហាវារំ វិត្ថារេតព្វំ ។

## វេទនាត្តិកេ នវេទនាត្តិកំ

[១៩] សុខាយ វេទនាយ សម្បយុត្តំ ធម្មំ បដិច្ច នសុខាយ វេទនាយ សម្បយុត្តោ ធម្មោ ឧប្បជ្ជតិ ហេតុប្បច្ចយា សុខាយ វេទនាយ សម្បយុត្តេ ខន្ធេ បដិច្ច សុខវេទនា ចិត្តសមុដ្ឋានញ្ច រូបំ បដិសន្ធិក្ខណេ មហាភូតា នត្ថិ ។ សុខាយ វេទនាយ សម្បយុត្តំ ធម្មំ បដិច្ច នទុក្ខាយ វេទនាយ សម្បយុត្តោ ធម្មោ ឧប្បជ្ជតិ ហេតុប្បច្ចយា សុខាយ វេទនាយ សម្បយុត្តំ ឯកំ ខន្ធំ បដិច្ច តយោ ខន្ធា ចិត្តសមុដ្ឋានញ្ច រូបំ ។

[១៨] ក្នុងហេតុប្បច្ច័យ មានវារៈ ១៣ ក្នុងអារម្មណប្បច្ច័យ មានវារៈ ១៨ ក្នុងអធិបតិប្បច្ច័យ មានវារៈ ១៧ ក្នុងអនន្តរប្បច្ច័យ មានវារៈ ១៦ ក្នុងសមនន្តរប្បច្ច័យ មានវារៈ ១៦ ក្នុងសហជាតប្បច្ច័យ មានវារៈ ១៩ ក្នុងអញ្ញមញ្ញប្បច្ច័យ មានវារៈ ៩ ក្នុងនិស្សយប្បច្ច័យ មានវារៈ ២៦ ក្នុងឧបនិស្សយប្បច្ច័យ មានវារៈ ១៨ ក្នុងបុរេជាតប្បច្ច័យ មានវារៈ ៦ ក្នុងបច្ឆាជាតប្បច្ច័យ មានវារៈ ៩ ក្នុងកម្មប្បច្ច័យ មានវារៈ ១៣ ក្នុងវិបាកប្បច្ច័យ មានវារៈ ៣ ក្នុងអាហារប្បច្ច័យ មានវារៈ ១៣ ។ បេ ។ ក្នុងមគ្គប្បច្ច័យ មានវារៈ ១៣ ក្នុងសម្បយុត្តប្ប-ច្ច័យ មានវារៈ ៩ ក្នុងវិប្បយុត្តប្បច្ច័យ មានវារៈ ១២ ។ បេ ។ ក្នុងអវិគតប្បច្ច័យ មានវារៈ ២៦ ។

បញ្ហាវារៈ បណ្ឌិត គប្បីឲ្យពិស្តារផងចុះ ។

## វេទនាត្តិកៈ នវេទនាត្តិកៈ

[១៩] ធម៌ ដែលមិនប្រកបដោយសុខវេទនា អាស្រ័យ នូវធម៌ ដែលប្រកបដោយសុខវេទនា ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺ សុខវេទនាផង ចិត្តសមុដ្ឋានរូបផង អាស្រ័យ នូវពួកខន្ធ ដែលប្រកបដោយសុខវេទនា ពួកមហាភូត មិនមាន ក្នុងខណៈនៃបដិសន្ធិទេ ។ ធម៌ ដែលមិនប្រកបដោយទុក្ខវេទនា អាស្រ័យ នូវធម៌ ដែលប្រកបដោយសុខវេទនា ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺ ខន្ធ ៣ ផង ចិត្តសមុដ្ឋានរូបផង អាស្រ័យ នូវខន្ធ ១ ដែលប្រកបដោយសុខវេទនា ។

៩

## អនុលោមប្បច្ចនីយត្តិកបដ្ឋានំ

សុខាយ វេទនាយ សម្បយុត្តំ ធម្មំ បដិច្ច នអទុក្ខ-
មសុខាយ វេទនាយ សម្បយុត្តោ ធម្មោ ឧប្បជ្ជតិ ហេ-
តុប្បច្ចយា សុខាយ វេទនាយ សម្បយុត្តំ ធម្មំ បដិច្ច
នសុខាយ វេទនាយ សម្បយុត្តោ ច នអទុក្ខមសុ-
ខាយ វេទនាយ សម្បយុត្តោ ច ធម្មា ឧប្បជ្ជន្តិ ហេ-
តុប្បច្ចយា សុខាយ វេទនាយ សម្បយុត្តំ ធម្មំ បដិច្ច
នទុក្ខាយ វេទនាយ សម្បយុត្តោ ច នអទុក្ខមសុខា-
យ វេទនាយ សម្បយុត្តោ ច ធម្មា ឧប្បជ្ជន្តិ ហេតុ-
ប្បច្ចយា សុខាយ វេទនាយ សម្បយុត្តំ ធម្មំ បដិច្ច
នសុខាយ វេទនាយ សម្បយុត្តោ ច នទុក្ខាយ វេទ-
នាយ សម្បយុត្តោ ច ធម្មា ឧប្បជ្ជន្តិ ហេតុប្បច្ចយា
សុខាយ វេទនាយ សម្បយុត្តំ ធម្មំ បដិច្ច នសុខា-
យ វេទនាយ សម្បយុត្តោ ច នទុក្ខាយ វេទនាយ
សម្បយុត្តោ ច នអទុក្ខមសុខាយ វេទនាយ សម្ប-
យុត្តោ ច ធម្មា ឧប្បជ្ជន្តិ ហេតុប្បច្ចយា សត្ត ។

[២០] ទុក្ខាយ វេទនាយ សម្បយុត្តំ ធម្មំ បដិច្ច
នទុក្ខាយ វេទនាយ សម្បយុត្តោ ធម្មោ ឧប្បជ្ជតិ
ហេតុប្បច្ចយា ទុក្ខាយ វេទនាយ សម្បយុត្តំ ធម្មំ
បដិច្ច នសុខាយ វេទនាយ សម្បយុត្តោ ធម្មោ

អនុលោមប្បច្ចនីយត្តិកប្បដ្ឋាន

ធម៌ ដែលមិនប្រកប ដោយវេទនាមិនមែនជាទុក្ខមិនមែនជាសុខ អា-ស្រ័យ នូវធម៌ ដែលប្រកបដោយសុខវេទនា ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ធម៌ ដែលមិនប្រកបដោយសុខវេទនាក្តី មិនប្រកបដោយវេទនាមិនមែនជាទុក្ខមិនមែនជាសុខក្តី អាស្រ័យ នូវធម៌ ដែលប្រកបដោយសុខវេទនា ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ធម៌ ដែលមិនប្រកបដោយទុក្ខវេទនាក្តី ដែលមិនប្រកបដោយវេទនាមិនមែនជាទុក្ខមិនមែនជាសុខក្តី អាស្រ័យ នូវធម៌ ដែលប្រកបដោយសុខវេទនា ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ធម៌ ដែលមិនប្រកបដោយសុខវេទនាក្តី ដែលមិនប្រកបដោយទុក្ខវេទនាក្តី អាស្រ័យ នូវធម៌ ដែលប្រកបដោយសុខវេទនា ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ធម៌ ដែលមិនប្រកបដោយសុខវេទនាក្តី ដែលមិនប្រកបដោយទុក្ខវេទនាក្តី ដែលមិនប្រកបដោយវេទនាមិនមែនជាទុក្ខមិនមែនជាសុខក្តី អាស្រ័យ នូវធម៌ ដែលប្រកបដោយសុខវេទនា ទើបកើតឡើង ព្រោះហេតុប្បច្ច័យ មានវារៈ ៧ ។

[២០] ធម៌ ដែលមិនប្រកបដោយទុក្ខវេទនា អាស្រ័យ នូវធម៌ ដែលប្រកបដោយទុក្ខវេទនា ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ធម៌ ដែលមិនប្រកបដោយសុខវេទនា អាស្រ័យ នូវធម៌ ដែលប្រកបដោយទុក្ខវេទនា

ឧប្បជ្ជតិ ហេតុប្បច្ចយា ទុក្ខាយ វេទនាយ សម្បយុត្តំ ធម្មំ បដិច្ច នអទុក្ខមសុខាយ វេទនាយ សម្បយុត្តោ ធម្មោ ឧប្បជ្ជតិ ហេតុប្បច្ចយា ទុក្ខាយ វេទនាយ សម្បយុត្តំ ធម្មំ បដិច្ច នសុខាយ វេទនាយ សម្បយុត្តោ ច នអទុក្ខមសុខាយ វេទនាយ សម្បយុត្តោ ច ធម្មា ឧប្បជ្ជន្តិ ហេតុប្បច្ចយា ទុក្ខាយ វេទនាយ សម្បយុត្តំ ធម្មំ បដិច្ច នទុក្ខាយ វេទនាយ សម្បយុត្តោ ច នអទុក្ខមសុខាយ វេទនាយ សម្បយុត្តោ ច ធម្មា ឧប្បជ្ជន្តិ ហេតុប្បច្ចយា ទុក្ខាយ វេទនាយ សម្បយុត្តំ ធម្មំ បដិច្ច នសុខាយ វេទនាយ សម្បយុត្តោ ច នទុក្ខាយ វេទនាយ សម្បយុត្តោ ច ធម្មា ឧប្បជ្ជន្តិ ហេតុប្បច្ចយា ទុក្ខាយ វេទនាយ សម្បយុត្តំ ធម្មំ បដិច្ច នសុខាយ វេទនាយ សម្បយុត្តោ ច នទុក្ខាយ វេទនាយ សម្បយុត្តោ ច នអទុក្ខមសុខាយ វេទនាយ សម្បយុត្តោ ច ធម្មា ឧប្បជ្ជន្តិ ហេតុប្បច្ចយា សត្ត ។

[២១] អទុក្ខមសុខាយ វេទនាយ សម្បយុត្តំ ធម្មំ បដិច្ច នអទុក្ខមសុខាយ វេទនាយ សម្បយុត្តោ ធម្មោ

ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ធម៌ ដែលប្រកបដោយវេទនាមិនមែនជាទុក្ខមិនមែនជាសុខ អាស្រ័យ នូវធម៌ ដែលប្រកបដោយទុក្ខ-វេទនា ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ធម៌ ដែលមិនប្រកបដោយសុខវេទនាក្តី ដែលមិនប្រកបដោយវេទនាមិនមែនជាទុក្ខមិនមែនជាសុខក្តី អាស្រ័យ នូវធម៌ ដែលប្រកបដោយទុក្ខវេទនា ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ធម៌ ដែលមិនប្រកបដោយទុក្ខវេទនាក្តី ដែលមិនប្រកបដោយវេទនាមិនមែនជាទុក្ខមិនមែនជាសុខក្តី អាស្រ័យ នូវធម៌ ដែលប្រកបដោយទុក្ខវេទនា ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ធម៌ ដែលមិនប្រកបដោយសុខវេទនាក្តី ដែលមិនប្រកបដោយទុក្ខវេទនាក្តី អាស្រ័យ នូវធម៌ ដែលប្រកបដោយទុក្ខវេទនា ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ធម៌ ដែលមិនប្រកបដោយសុខវេទនាក្តី ដែលមិនប្រកបដោយទុក្ខវេទនាក្តី ដែលមិនប្រកបដោយវេទនាមិនមែនជាទុក្ខមិនមែនជាសុខក្តី អាស្រ័យ នូវធម៌ ដែលប្រកបដោយទុក្ខវេទនា ទើបកើតឡើង ព្រោះហេតុប្បច្ច័យ មានវារៈ ៧ ។

[២១] ធម៌ ដែលប្រកបដោយវេទនាមិនមែនជាទុក្ខមិនមែនជាសុខ អាស្រ័យ នូវធម៌ ដែលប្រកបដោយវេទនាមិនមែនជាទុក្ខមិនមែនជាសុខ

## អនុលោមប្បច្ចនីយត្តិកប្បដ្ឋានំ

ឧប្បជ្ជតិ ហេតុប្បច្ចយា អទុក្ខមសុខាយ វេទនាយ សម្បយុត្តំ ធម្មំ បដិច្ច នសុខាយ វេទនាយ សម្បយុត្តោ ធម្មោ ឧប្បជ្ជតិ ហេតុប្បច្ចយា អទុក្ខមសុខាយ វេទនាយ សម្បយុត្តំ ធម្មំ បដិច្ច នទុក្ខាយ វេទនាយ សម្បយុត្តោ ធម្មោ ឧប្បជ្ជតិ ហេតុប្បច្ចយា អទុក្ខមសុខាយ វេទនាយ សម្បយុត្តំ ធម្មំ បដិច្ច នសុខាយ វេទនាយ សម្បយុត្តោ ច នអទុក្ខមសុខាយ វេទនាយ សម្បយុត្តោ ច ធម្មា ឧប្បជ្ជន្តិ ហេតុប្បច្ចយា អទុក្ខមសុខាយ វេទនាយ សម្បយុត្តំ ធម្មំ បដិច្ច នទុក្ខាយ វេទនាយ សម្បយុត្តោ ច នអទុក្ខមសុខាយ វេទនាយ សម្បយុត្តោ ច ធម្មា ឧប្បជ្ជន្តិ ហេតុប្បច្ចយា អទុក្ខមសុខាយ វេទនាយ សម្បយុត្តំ ធម្មំ បដិច្ច នសុខាយ វេទនាយ សម្បយុត្តោ ច នទុក្ខាយ វេទនាយ សម្បយុត្តោ ច ធម្មា ឧប្បជ្ជន្តិ ហេតុប្បច្ចយា អទុក្ខមសុខាយ វេទនាយ សម្បយុត្តំ ធម្មំ បដិច្ច នសុខាយ វេទនាយ សម្បយុត្តោ ច នទុក្ខាយ វេទនាយ សម្បយុត្តោ ច នអទុក្ខមសុខាយ វេទនាយ សម្បយុត្តោ ច ធម្មា ឧប្បជ្ជន្តិ ហេតុប្បច្ចយា សត្ត ។

ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ធម៌ ដែលមិនប្រកបដោយសុខ-វេទនា អាស្រ័យ នូវធម៌ ដែលប្រកបដោយវេទនាមិនមែនជាទុក្ខមិនមែនជាសុខ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ធម៌ ដែលមិនប្រកបដោយទុក្ខវេទនា អាស្រ័យ នូវធម៌ ដែលប្រកបដោយវេទនាមិនមែនជាទុក្ខមិនមែនជាសុខ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ធម៌ ដែលមិនប្រកបដោយសុខវេទនាក្តី ដែលមិនប្រកបដោយវេទនាមិនមែនជាទុក្ខមិនមែនជាសុខក្តី អាស្រ័យ នូវធម៌ ដែលប្រកបដោយវេទនាមិនមែនជាទុក្ខមិនមែនជាសុខ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ធម៌ ដែលមិនប្រកបដោយទុក្ខវេទនាក្តី ដែលមិនប្រកបដោយវេទនាមិនមែនជាទុក្ខមិនមែនជាសុខក្តី អាស្រ័យ នូវធម៌ ដែលប្រកបដោយវេទនាមិនមែនជាទុក្ខមិនមែនជាសុខ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ធម៌ ដែលមិនប្រកបដោយសុខវេទនាក្តី ដែលមិនប្រកបដោយទុក្ខវេទនាក្តី អាស្រ័យ នូវធម៌ ដែលប្រកបដោយវេទនាមិនមែនជាទុក្ខមិនមែនជាសុខ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ធម៌ ដែលមិនប្រកបដោយសុខវេ-ទនាក្តី ដែលមិនប្រកបដោយទុក្ខវេទនាក្តី ដែលមិនប្រកបដោយវេទនាមិនមែនជាទុក្ខមិនមែនជាសុខក្តី អាស្រ័យ នូវធម៌ ដែលប្រកបដោយវេទនា មិនមែនជាទុក្ខមិនមែនជាសុខ ទើបកើតឡើង ព្រោះហេតុ-ប្បច្ច័យ មានវារៈ ៧ ។

[២២] ហេតុយា ឯកាវីស អារម្មណេ ឯកាវីស អវិគតេ ឯកាវីស ។

[២៣] សុខាយ វេទនាយ សម្បយុត្តំ ធម្មំ បដិច្ច នសុខាយ វេទនាយ សម្បយុត្តោ ធម្មោ ឧប្បជ្ជតិ នហេតុប្បច្ចយា ។

[២៤] នហេតុយា ឯកាវីស នអារម្មណេ ឯកាវីស នវិប្បយុត្តេ ចុទ្ទស នោវិគតេ ឯកាវីស ។

សហជាតវារម្បិ បច្ចយវារម្បិ និស្សយវារម្បិ
សំសដ្ឋវារម្បិ សម្បយុត្តវារម្បិ បដិច្ចវារសទិសំ ។

[២៥] សុខាយ វេទនាយ សម្បយុត្តោ ធម្មោ នសុខាយ វេទនាយ សម្បយុត្តស្ស ធម្មស្ស ហេតុប្បច្ចយេន បច្ចយោ សុខាយ វេទនាយ សម្បយុត្តោ ធម្មោ នទុក្ខាយ វេទនាយ សម្បយុត្តស្ស ធម្មស្ស ហេតុប្បច្ចយេន បច្ចយោ សុខាយ វេទនាយ សម្បយុត្តោ ធម្មោ នអទុក្ខមសុខាយ វេទនាយ សម្បយុត្តស្ស ធម្មស្ស ហេតុប្បច្ចយេន បច្ចយោ សុខាយ វេទនាយ សម្បយុត្តោ ធម្មោ នសុខាយ វេទនាយ សម្បយុត្តស្ស ច នអទុក្ខមសុខាយ វេទនាយ សម្បយុត្តស្ស ច ធម្មស្ស ហេតុប្បច្ចយេន បច្ចយោ

[២២] ក្នុងហេតុប្បច្ច័យ មានវារៈ ២១ ក្នុងអារម្មណប្បច្ច័យ មានវារៈ ២១ ក្នុងអវិគតប្បច្ច័យ មានវារៈ ២១ ។

[២៣] ធម៌ ដែលមិនប្រកបដោយសុខវេទនា អាស្រ័យ នូវធម៌ ដែលប្រកបដោយសុខវេទនា ទើបកើតឡើង ព្រោះនហេតុប្បច្ច័យ ។

[២៤] ក្នុងនហេតុប្បច្ច័យ មានវារៈ ២១ ក្នុងនអារម្មណប្បច្ច័យ មានវារៈ ២១ ក្នុងនវិប្បយុត្តប្បច្ច័យ មានវារៈ ១៤ ក្នុងនោវិគតប្បច្ច័យ មានវារៈ ២១ ។

សហជាតវារៈក្តី បច្ចយវារៈក្តី និស្សយវារៈក្តី សំសដ្ឋវារៈក្តី
សម្បយុត្តវារៈក្តី ប្រហែលគ្នានឹងបដិច្ចវារៈដែរ ។

[២៥] ធម៌ ដែលប្រកបដោយសុខវេទនា ជាបច្ច័យ នៃ ធម៌ ដែលមិនប្រកបដោយសុខវេទនា ដោយហេតុប្បច្ច័យ ធម៌ ដែល ប្រកបដោយសុខវេទនា ជាបច្ច័យ នៃធម៌ ដែលមិនប្រកបដោយទុក្ខ-វេទនា ដោយហេតុប្បច្ច័យ ធម៌ ដែលប្រកបដោយសុខវេទនា ជា បច្ច័យ នៃធម៌ ដែលមិនប្រកបដោយវេទនាមិនមែនជាទុក្ខមិនមែន ជាសុខ ដោយហេតុប្បច្ច័យ ធម៌ ដែលប្រកបដោយសុខវេទនា ជាបច្ច័យ នៃធម៌ ដែលមិនប្រកបដោយសុខវេទនាផង ដែលមិន ប្រកបដោយវេទនាមិនមែនជាទុក្ខមិនមែនជាសុខផង ដោយហេតុប្បច្ច័យ

សុខាយ វេទនាយ សម្បយុត្តោ ធម្មោ ទុក្ខាយ វេទ-
នាយ សម្បយុត្តស្ស ច អទុក្ខមសុខាយ វេទនាយ
សម្បយុត្តស្ស ច ធម្មស្ស ហេតុប្បច្ចយេន បច្ចយោ
សុខាយ វេទនាយ សម្បយុត្តោ ធម្មោ សុខាយ
វេទនាយ សម្បយុត្តស្ស ច ទុក្ខាយ វេទនាយ
សម្បយុត្តស្ស ច ធម្មស្ស ហេតុប្បច្ចយេន បច្ចយោ
សុខាយ វេទនាយ សម្បយុត្តោ ធម្មោ សុខាយ វេ-
ទនាយ សម្បយុត្តស្ស ច ទុក្ខាយ វេទនាយ សម្ប-
យុត្តស្ស ច អទុក្ខមសុខាយ វេទនាយ សម្បយុ-
ត្តស្ស ច ធម្មស្ស ហេតុប្បច្ចយេន បច្ចយោ សត្ត ។

[២៦] ហេតុយា ឯកវីស អារម្មណេ ឯកវីស
អវិគតេ ឯកវីស ។

បញ្ហាវារំ វិត្ថារេតព្វំ ។

## វិបាកត្តិកេ នវិបាកត្តិកំ

[២៧] វិបាកំ ធម្មំ បដិច្ច នវិបាកោ ធម្មោ ឧប្ប-
ជ្ជតិ ហេតុប្បច្ចយា វិបាកំ ធម្មំ បដិច្ច នវិបាកធម្ម-
ធម្មោ ឧប្បជ្ជតិ ហេតុប្បច្ចយា វិបាកំ ធម្មំ បដិច្ច
ន នេវវិបាកនវិបាកធម្មធម្មោ ឧប្បជ្ជតិ ហេតុប្បច្ចយា

ធម៌ ដែលប្រកបដោយសុខវេទនា ជាបច្ច័យ នៃធម៌ ដែលមិនប្រកបដោយទុក្ខវេទនាផង ដែលមិនប្រកបដោយវេទនាមិនមែនជាទុក្ខមិនមែនជាសុខផង ដោយហេតុប្បច្ច័យ ធម៌ ដែលប្រកបដោយសុខវេទនា ជាបច្ច័យ នៃធម៌ ដែលមិនប្រកបដោយសុខវេទនាផង ដែលមិនប្រកបដោយទុក្ខវេទនាផង ដោយហេតុប្បច្ច័យ ធម៌ ដែលប្រកបដោយសុខ-វេទនា ជាបច្ច័យ នៃធម៌ ដែលមិនប្រកបដោយសុខវេទនាផង ដែលមិនប្រកបដោយទុក្ខវេទនាផង ដែលមិនប្រកបដោយវេទនាមិនមែនជាទុក្ខមិនមែនជាសុខផង ដោយហេតុប្បច្ច័យ មានវារៈ ៧ ។

[២៦] ក្នុងហេតុប្បច្ច័យ មានវារៈ ២១ ក្នុងអារម្មណប្បច្ច័យ មានវារៈ ២១ ក្នុងអវិគតប្បច្ច័យ មានវារៈ ២១ ។

បញ្ហាវារៈ បណ្ឌិត គប្បីឲ្យពិស្តារផងចុះ ។

# វិបាកត្តិកៈ នវិបាកត្តិកៈ

[២៧] ធម៌ មិនមែនជាវិបាក អាស្រ័យ នូវធម៌ ជាវិបាក ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ធម៌ មិនមែនមានវិបាកជាប្រក្រតី អាស្រ័យ នូវធម៌ ជាវិបាក ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ធម៌ មិនមែនជាមិនមែនវិបាក ទាំងមិនមែនជាមានវិបាកជាប្រក្រតី អាស្រ័យ នូវធម៌ ជាវិបាក ទើបកើតឡើង ព្រោះហេតុប្បច្ច័យ

វិបាកំ ធម្មំ បដិច្ច ន វិបាកធម្មធម្មោ ច ន នេវវិបាកនវិបាកធម្មធម្មោ ច ធម្មា ឧប្បជ្ជន្តិ ហេតុប្បច្ចយា វិបាកំ ធម្មំ បដិច្ច ន វិបាកោ ច ន វិបាកធម្មធម្មោ ច ធម្មា ឧប្បជ្ជន្តិ ហេតុប្បច្ចយា បញ្ច ។

[២៨] វិបាកធម្មធម្មំ បដិច្ច ន វិបាកធម្មធម្មោ ឧប្បជ្ជតិ ហេតុប្បច្ចយា វិបាកធម្មធម្មំ បដិច្ច ន វិបាកោ ធម្មោ ឧប្បជ្ជតិ ហេតុប្បច្ចយា វិបាកធម្មធម្មំ បដិច្ច ន នេវវិបាកនវិបាកធម្មធម្មោ ឧប្បជ្ជតិ ហេតុប្បច្ចយា វិបាកធម្មធម្មំ បដិច្ច ន វិបាកោ ច ន នេវវិបាកនវិបាកធម្មធម្មោ ច ធម្មា ឧប្បជ្ជន្តិ ហេតុប្បច្ចយា វិបាកធម្មធម្មំ បដិច្ច ន វិបាកោ ច ន វិបាកធម្មធម្មោ ច ធម្មា ឧប្បជ្ជន្តិ ហេតុប្បច្ចយា បញ្ច ។

[២៩] នេវវិបាកនវិបាកធម្មធម្មំ បដិច្ច ន នេវវិបាកនវិបាកធម្មធម្មោ ឧប្បជ្ជតិ ហេតុប្បច្ចយា នេវវិបាកនវិបាកធម្មធម្មំ បដិច្ច នវិបាកោ ធម្មោ

ធម៌ មិនមែនជាធម៌មានវិបាកជាប្រក្រតីក្តី មិនមែនជាមិនមានវិបាកទាំងមិនមែនជាធម៌មានវិបាកជាប្រក្រតីក្តី អាស្រ័យ នូវធម៌ ជាវិបាក ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ធម៌ មិនមែនជាវិបាកក្តី មិនមែនជាធម៌មានវិបាកជាប្រក្រតីក្តី អាស្រ័យ នូវធម៌ ជាវិបាក ទើបកើតឡើង ព្រោះហេតុប្បច្ច័យ មានវារៈ ៥ ។

[២៨] ធម៌ មិនមែនជាមានវិបាកជាប្រក្រតី អាស្រ័យ នូវធម៌ មានវិបាកជាប្រក្រតី ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ធម៌ មិនមែនជាវិបាក អាស្រ័យ នូវធម៌ មានវិបាកជាប្រក្រតី ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ធម៌ មិនមែនជាមិនមែនជាវិបាកទាំងមិនមែនជាមានវិ-បាកជាប្រក្រតី អាស្រ័យ នូវធម៌ មានវិបាកជាប្រក្រតី ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ធម៌ មិនមែនជាវិបាកក្តី មិនមែនជាមិនមែនជាវិបាកទាំងមិនមែនជាធម៌មានវិបាកជាប្រក្រតីក្តី អាស្រ័យ នូវធម៌ មានវិបាកជាប្រក្រតី ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ធម៌ មិនមែនជាវិបាកក្តី មិនមែនជាធម៌មានវិបាកជាប្រក្រតីក្តី អាស្រ័យ នូវធម៌ មានវិបាកជាប្រក្រតី ទើបកើតឡើង ព្រោះហេតុប្បច្ច័យ មានវារៈ ៥ ។

[២៩] ធម៌ មិនមែនជាមិនមែនជាវិបាកទាំងមិនមែនជាមានវិបាកជាប្រក្រតី អាស្រ័យ នូវធម៌ មិនមែនជាវិបាកទាំងមិនមែនជាមានវិបាកជាប្រក្រតី ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ធម៌ មិនមែនជាវិបាក អាស្រ័យ នូវធម៌ មិនមែនជាវិបាកទាំងមិនមែនជាមានវិបាកជាប្រក្រតី

អនុលោមប្បច្ចនីយត្តិកប្បដ្ឋានំ

ឧប្បជ្ជតិ ហេតុប្បច្ចយា នេវវិចាកនវិចាកធម្មធម្មំ បដិច្ច នវិចាកធម្មធម្មោ ឧប្បជ្ជតិ ហេតុប្បច្ចយា នេវវិចាកនវិចាកធម្មធម្មំ បដិច្ច នវិចាកធម្មធម្មោ ច ននេវវិចាកនវិចាកធម្មធម្មោ ច ធម្មា ឧប្បជ្ជន្តិ ហេតុប្បច្ចយា នេវវិចាកនវិចាកធម្មធម្មំ បដិច្ច នវិចាកោ ច នវិចាកធម្មធម្មោ ច ធម្មា ឧប្បជ្ជន្តិ ហេតុប្បច្ចយា បញ្ច ។

[៣០] វិចាកញ្ច នេវវិចាកនវិចាកធម្មធម្មញ្ច ធម្មំ បដិច្ច នវិចាកោ ធម្មោ ឧប្បជ្ជតិ ហេតុប្បច្ចយា វិចាកញ្ច នេវវិចាកនវិចាកធម្មធម្មញ្ច ធម្មំ បដិច្ច នវិចាកធម្មធម្មោ ឧប្បជ្ជតិ ហេតុប្បច្ចយា វិចាកញ្ច នេវវិចាកនវិចាកធម្មធម្មញ្ច ធម្មំ បដិច្ច ននេវវិចាកនវិចាកធម្មធម្មោ ឧប្បជ្ជតិ ហេតុប្បច្ចយា វិចាកញ្ច នេវវិចាកនវិចាកធម្មធម្មញ្ច ធម្មំ បដិច្ច នវិចាកធម្មធម្មោ ច ននេវវិចាកនវិចាកធម្មធម្មោ ច ធម្មា ឧប្បជ្ជន្តិ

ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ធម៌ មិនមែនមានវិបាកជាប្រក្រតី អាស្រ័យ នូវធម៌ មិនមែនជាវិបាកទាំងមិនមែនជាមានវិបាកជាប្រក្រតី ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ធម៌ មិនមែនជាធម៌មានវិបាកជាប្រក្រតីក្តី មិនមែនជាមិនមែនវិបាកទាំងមិនមែនជាធម៌មានវិបាកជាប្រក្រតីក្តី អាស្រ័យ នូវធម៌ មិនមែនជាវិបាកទាំងមិនមែនមានវិបាកជាប្រក្រតី ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ធម៌ មិនមែនជាវិបាកក្តី មិនមែនជាធម៌មានវិបាកជាប្រក្រតីក្តី អាស្រ័យ នូវធម៌ មិនមែនជាវិបាកទាំងមិនមែនជាមានវិបាកជាប្រក្រតី ទើបកើតឡើង ព្រោះហេតុប្បច្ច័យ មានវារៈ ៥ ។

[៣០] ធម៌ មិនមែនជាវិបាក អាស្រ័យ នូវធម៌ ជាវិបាកផង មិនមែនជាវិបាកទាំងមិនមែនជាធម៌មានវិបាកជាប្រក្រតីផង ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ធម៌ មិនមែនមានវិបាកជាប្រក្រតី អាស្រ័យ នូវធម៌ជាវិបាកផង មិនមែនជាវិបាកទាំងមិនមែនជាធម៌មានវិបាកជាប្រក្រតីផង ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ធម៌ មិនមែនជាមិនមែនវិបាកទាំងមិនមែនជាមានវិបាកជាប្រក្រតី អាស្រ័យ នូវធម៌ ជាវិបាកផង មិនមែនជាវិបាកទាំងមិនមែនជាធម៌មានវិបាកជាប្រក្រតីផង ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ធម៌ មិនមែនជាធម៌មានវិបាកជាប្រក្រតីក្តី មិនមែនជាមិនមែនវិបាកទាំងមិនមែនជាធម៌មានវិបាកជាប្រក្រតីក្តី អាស្រ័យ នូវធម៌ ជាវិបាកផង មិនមែនជាវិបាកទាំងមិនមែនជាធម៌មានវិបាកជាប្រក្រតីផង ទើបកើតឡើង

ហេតុបច្ចយា វិបាកញ្ច នេវវិបាកនវិបាកធម្មធម្មញ្ច ធម្មំ បដិច្ច នវិបាកោ ច នវិបាកធម្មធម្មោ ច ធម្មា ឧប្បជ្ជន្តិ ហេតុបច្ចយា បញ្ច ។

[៣១] វិបាកធម្មធម្មញ្ច នេវវិបាកនវិបាកធម្មធម្មញ្ច ធម្មំ បដិច្ច នវិបាកោ ធម្មោ ឧប្បជ្ជតិ ហេតុបច្ចយា វិបាកធម្មធម្មញ្ច នេវវិបាកនវិបាកធម្មធម្មញ្ច ធម្មំ បដិច្ច នវិបាកធម្មធម្មោ ឧប្បជ្ជតិ ហេតុបច្ចយា វិបាកធម្មធម្មញ្ច នេវវិបាកនវិបាកធម្មធម្មញ្ច ធម្មំ បដិច្ច នវិបាកោ ច ននេវវិបាកនវិបាកធម្មធម្មោ ច ធម្មា ឧប្បជ្ជន្តិ ហេតុបច្ចយា តីណិ ។

[៣២] វិបាកំ ធម្មំ បដិច្ច នវិបាកធម្មធម្មោ ឧប្បជ្ជតិ អារម្មណប្បច្ចយា តីណិ ។ វិបាកធម្មធម្មំ បដិច្ច នវិបាកោ ធម្មោ ឧប្បជ្ជតិ អារម្មណប្បច្ចយា តីណិ ។ នេវវិបាកនវិបាកធម្មធម្មំ បដិច្ច ននេវវិបាកនវិបាកធម្មធម្មោ ឧប្បជ្ជតិ អារម្មណប្បច្ចយា

ព្រោះហេតុប្បច្ច័យ ធម៌ មិនមែនជាវិបាកក្តី មិនមែនជាធម៌មានវិបាកជាប្រ-ក្រតីក្តី អាស្រ័យ នូវធម៌ ជាវិបាកផង មិនមែនជាវិបាកទាំងមិនមែនជាធម៌មានវិបាកជាប្រក្រតីផង ទើបកើតឡើង ព្រោះហេតុប្បច្ច័យ មានវារៈ ៥ ។

[៣១] ធម៌ មិនមែនជាវិបាក អាស្រ័យ នូវធម៌ ជាធម៌មានវិបាកជាប្រក្រតីផង មិនមែនជាវិបាកទាំងមិនមែនជាធម៌មានវិបាកជាប្រក្រតីផង ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ធម៌ មិនមែនជាមានវិបាកជាប្រក្រតី អាស្រ័យ នូវធម៌ ជាធម៌មានវិបាកជាប្រក្រតីផង មិនមែនជាវិបាកទាំងមិនមែនជាធម៌មានវិបាកជាប្រក្រតីផង ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ធម៌ មិនមែនជាវិបាកក្តី មិនមែនជាមិនមែនជាវិបាកទាំងមិនមែនជាធម៌មានវិបាកជាប្រក្រតីក្តី អាស្រ័យ នូវធម៌ ជាធម៌មានវិបាកជាប្រក្រតីផង មិនមែនជាវិបាកទាំងមិនមែនជាធម៌មានវិបាកជាប្រក្រតីផង ទើបកើតឡើង ព្រោះហេតុប្បច្ច័យ មានវារៈ ៣ ។

[៣២] ធម៌ មិនមែនមានវិបាកជាប្រក្រតី អាស្រ័យ នូវធម៌ ជាវិបាក ទើបកើតឡើង ព្រោះអារម្មណប្បច្ច័យ មានវារៈ ៣ ។ ធម៌ មិនមែនជាវិបាក អាស្រ័យ នូវធម៌ មានវិបាកជាប្រក្រតី ទើបកើតឡើង ព្រោះអារម្មណប្បច្ច័យ មានវារៈ ៣ ។ ធម៌ មិនមែនជាមិនមែនជាវិបាកទាំងមិនមែនជាមានវិបាកជាប្រក្រតី អាស្រ័យ នូវធម៌ មិនមែនជាវិបាកទាំងមិនមែនជាមានវិបាកជាប្រក្រតី ទើបកើតឡើង ព្រោះអារម្មណប្បច្ច័យ

បញ្ច ។ វិបាកញ្ច នេវវិបាកនវិបាកធម្មធម្មញ្ច ធម្មំ បដិច្ច នវិបាកធម្មធម្មោ ឧប្បជ្ជតិ អារម្មណាប្បច្ចយា តីណិ ។

[៣៣] ហេតុយា តេវីស អារម្មណេ ចុទ្ទស ។ បេ ។ អវិគតេ តេវីស ។

[៣៤] នហេតុយា អដ្ឋារស នអារម្មណេ បណ្ណរស ។ សហជាតវារម្បិ បច្ចយវារម្បិ និស្សយវារម្បិ សំសដ្ឋវារម្បិ សម្បយុត្តវារម្បិ វិត្ថារេតព្វំ ។

[៣៥] វិបាកោ ធម្មោ នវិបាកស្ស ធម្មស្ស ហេតុប្បច្ចយេន បច្ចយោ វិបាកោ ធម្មោ នវិបាក-ធម្មធម្មស្ស ហេតុប្បច្ចយេន បច្ចយោ វិបាកោ ធម្មោ ននេវវិបាកនវិបាកធម្មធម្មស្ស ហេតុប្បច្ចយេន បច្ច-យោ វិបាកោ ធម្មោ នវិបាកធម្មធម្មស្ស ច ននេវ-វិបាកនវិបាកធម្មធម្មស្ស ច ធម្មស្ស ហេតុប្បច្ចយេន បច្ចយោ វិបាកោ ធម្មោ នវិបាកស្ស ច នវិបាក-ធម្មធម្មស្ស ច ធម្មស្ស ហេតុប្បច្ចយេន បច្ចយោ បញ្ច ។

[៣៦] វិបាកោ ធម្មោ នវិបាកស្ស ធម្មស្ស អារម្មណាប្បច្ចយេន បច្ចយោ វិបាកោ ធម្មោ

មានវារៈ ៤ ។ ធម៌ មិនមែនមានវិបាកជាប្រក្រតី អាស្រ័យ នូវធម៌ជាវិបាកផង មិនមែនជាវិបាកទាំងមិនមែនជាធម៌មានវិបាកជាប្រក្រតីផង ទើបកើតឡើង ព្រោះអារម្មណប្បច្ច័យ មានវារៈ ៣ ។

[៣៣] ក្នុងហេតុប្បច្ច័យ មានវារៈ ២៣ ក្នុងអារម្មណប្បច្ច័យ មានវារៈ ១៤ ។ បេ ។ ក្នុងអវិគតប្បច្ច័យ មានវារៈ ២៣ ។

[៣៤] ក្នុងនហេតុប្បច្ច័យ មានវារៈ ១៨ ក្នុងនអារម្មណប្បច្ច័យ មានវារៈ ១៥ ។

សហជាតវារៈក្តី បច្ចយវារៈក្តី និស្សយវារៈក្តី សំសដ្ឋវារៈក្តី
សម្បយុត្តវារៈក្តី បណ្ឌិត គប្បីឲ្យពិស្តារផងចុះ ។

[៣៥] ធម៌ ជាវិបាក ជាបច្ច័យ នៃធម៌ មិនមែនជាវិបាក ដោយហេតុប្បច្ច័យ ធម៌ ជាវិបាក ជាបច្ច័យ នៃធម៌ មិនមែនមានវិបាកជាប្រក្រតី ដោយហេតុប្បច្ច័យ ធម៌ ជាវិបាក ជាបច្ច័យ នៃធម៌ មិនមែនជាមិនមែនវិបាកទាំងមិនមែនជាមានវិបាកជាប្រក្រតី ដោយហេតុប្បច្ច័យ ធម៌ ជាវិបាក ជាបច្ច័យ នៃធម៌ មិនមែនជាធម៌មានវិបាកជាប្រក្រតីផង មិនមែនជាមិនមែនវិបាកទាំងមិនមែនជាធម៌មានវិបាកជាប្រក្រតីផង ដោយហេតុប្បច្ច័យ ធម៌ ជាវិបាក ជាបច្ច័យ នៃធម៌ មិនមែនជាវិបាកផង មិនមែនជាធម៌មានវិបាកជាប្រក្រតីផង ដោយហេតុប្បច្ច័យ មានវារៈ ៥ ។

[៣៦] ធម៌ ជាវិបាក ជាបច្ច័យ នៃធម៌ មិនមែនជាវិបាក ដោយអារម្មណប្បច្ច័យ ធម៌ ជាវិបាក

នវិបាកធម្មធម្មស្ស អារម្មណបច្ចយេន បច្ចយោ វិបា-
កោ ធម្មោ ននេវវិបាកនវិបាកធម្មធម្មស្ស អារម្ម-
ណបច្ចយេន បច្ចយោ វិបាកោ ធម្មោ នវិបាកស្ស
ច ននេវវិបាកនវិបាកធម្មធម្មស្ស ច ធម្មស្ស អារម្ម-
ណបច្ចយេន បច្ចយោ វិបាកោ ធម្មោ នវិបាកធម្ម-
ធម្មស្ស ច ននេវវិបាកនវិបាកធម្មធម្មស្ស ច ធម្មស្ស
អារម្មណបច្ចយេន បច្ចយោ វិបាកោ ធម្មោ នវិបា-
កស្ស ច នវិបាកធម្មធម្មស្ស ច ធម្មស្ស អារម្ម-
ណបច្ចយេន បច្ចយោ ៩ ។

[៣៧] វិបាកធម្មធម្មោ នវិបាកធម្មធម្មស្ស
អារម្មណបច្ចយេន បច្ចយោ វិបាកធម្មធម្មោ នវិបា-
កស្ស ធម្មស្ស អារម្មណបច្ចយេន បច្ចយោ វិបាក-
ធម្មធម្មោ ននេវវិបាកនវិបាកធម្មធម្មស្ស អារម្មណ-
បច្ចយេន បច្ចយោ វិបាកធម្មធម្មោ នវិបាកស្ស
ច ននេវវិបាកនវិបាកធម្មធម្មស្ស ច ធម្មស្ស អា-
រម្មណបច្ចយេន បច្ចយោ វិបាកធម្មធម្មោ នវិបាក-
ធម្មធម្មស្ស ច ននេវវិបាកនវិបាកធម្មធម្មស្ស ច
ធម្មស្ស អារម្មណបច្ចយេន បច្ចយោ វិបាកធម្មធម្មោ

ជាបច្ច័យ នៃធម៌មិនមែនជាមានវិបាកជាប្រក្រតី ដោយអារម្មណប្បច្ច័យ ធម៌ជាវិបាក ជាបច្ច័យ នៃធម៌ មិនមែនជាមិនមែនជាវិបាកទាំងមិនមែនជាធម៌មានវិបាកជាប្រក្រតី ដោយអារម្មណប្បច្ច័យ ធម៌ ជាវិបាក ជាបច្ច័យ នៃធម៌ មិនមែនជាវិបាកផង មិនមែនជាមិនមែនជាវិបាកទាំងមិនមែនមានវិ-បាកជាប្រក្រតីផង ដោយអារម្មណប្បច្ច័យ ធម៌ ជាវិបាក ជាបច្ច័យ នៃធម៌ មិនមែនជាធម៌មានវិបាកជាប្រក្រតីផង មិនមែនជាមិនមែនជាវិបាកទាំងមិនមែនជាធម៌មានវិបាកជាប្រក្រតីផង ដោយអារម្មណប្បច្ច័យ ធម៌ ជាវិបាក ជាបច្ច័យ នៃធម៌ មិនមែនជាវិបាកផង មិនមែនជាធម៌មានវិបាកជាប្រក្រតីផង ដោយអារម្មណប្បច្ច័យ មានវារៈ ៦ ។

[៣៧] ធម៌ មានវិបាកជាប្រក្រតី ជាបច្ច័យ នៃធម៌ មិនមែនមានវិបាកជាប្រក្រតី ដោយអារម្មណប្បច្ច័យ ធម៌ មានវិបាកជាប្រក្រតី ជាបច្ច័យ នៃធម៌ មិនមែនជាវិបាក ដោយអារម្មណប្បច្ច័យ ធម៌ មានវិបាកជាប្រក្រតី ជាបច្ច័យ នៃធម៌ មិនមែនជាមិនមែនជាវិបាកទាំងមិនមែនជាមានវិបាកជាប្រក្រតី ដោយអារម្មណប្បច្ច័យ ធម៌ មានវិបាកជាប្រក្រតី ជាបច្ច័យ នៃធម៌ មិនមែនជាវិបាកផង មិនមែនជាមិនមែនជាវិបាកទាំងមិនមែនជាធម៌មានវិបាកជាប្រក្រតីផង ដោយអារម្មណប្បច្ច័យ ធម៌មានវិបាកជាប្រក្រតី ជាបច្ច័យ នៃធម៌ មិនមែនជាធម៌មានវិបាកជាប្រក្រតីផង មិនមែនជាមិនមែនជាវិបាកទាំងមិនមែនជាធម៌មានវិបាកជាប្រក្រតីផង ដោយអារម្មណប្បច្ច័យ ធម៌ មានវិបាកជាប្រប្រតី

នវិបាកស្ស ច នវិបាកធម្មធម្មស្ស ច ធម្មស្ស អារម្មណប្បច្ចយេន បច្ចយោ ជ ។

[៣៨] នេវវិបាកនវិបាកធម្មធម្មោ ននេវវិបា-កនវិបាកធម្មធម្មស្ស អារម្មណប្បច្ចយេន បច្ចយោ ។ បេ ។ ជ ។

[៣៩] ហេតុយា តេរស អារម្មណេ អដ្ឋារស អធិបតិយា សត្តរស អនន្តរេ សោឡស ។ បេ ។ បុរេជាតេ ជ បច្ឆាជាតេ នវ អាសេវនេ ជ កម្មេ ចុទ្ទស វិបាកេ បញ្ច ។ បេ ។ ឥន្ទ្រិយេ អដ្ឋារស ។ បេ ។ វិប្បយុត្តេ ទ្វាទស អវិគតេ តេវីស ។

បញ្ហាវារំ វិត្ថារេតព្វំ ។

# ឧបាទិន្នុបាទានិយត្តិកេ

# នឧបាទិន្នុបាទានិយត្តិកំ

[៤០] ឧបាទិន្នុបាទានិយំ ធម្មំ បដិច្ច នឧ-បាទិន្នុបាទានិយោ ធម្មោ ឧប្បជ្ជតិ ហេតុប្បច្ចយា

ជាបច្ច័យ នៃធម៌ មិនមែនជាវិបាកផង មិនមែនជាធម៌មានវិបាកជាប្រ-ក្រតីផង ដោយអារម្មណប្បច្ច័យ មានវារៈ ៦ ។

[៣៨] ធម៌ មិនមែនជាវិបាកទាំងមិនមែនមានវិបាកជាប្រក្រតី ជាបច្ច័យ នៃធម៌ មិនមែនជាមិនមែនវិបាកទាំងមិនមែនជាមានវិបាកជា ប្រក្រតី ដោយអារម្មណប្បច្ច័យ ។ បេ ។ មានវារៈ ៦ ។

[៣៩] ក្នុងហេតុប្បច្ច័យ មានវារៈ ១៣ ក្នុងអារម្មណប្បច្ច័យ មានវារៈ ១៨ ក្នុងអធិបតិប្បច្ច័យ មានវារៈ ១៧ ក្នុងអនន្តរប្បច្ច័យ មានវារៈ ១៦ ។ បេ ។ ក្នុងបុរេជាតប្បច្ច័យ មានវារៈ ៦ ក្នុងបច្ឆាជាត-ប្បច្ច័យ មានវារៈ ៩ ក្នុងអាសេវនប្បច្ច័យ មានវារៈ ៦ ក្នុងកម្មប្បច្ច័យ មានវារៈ ១៤ ក្នុងវិបាកប្បច្ច័យ មានវារៈ ៥ ។ បេ ។ ក្នុងឥន្ទ្រិ-យប្បច្ច័យ មានវារៈ ១៨ ។ បេ ។ ក្នុងវិប្បយុត្តប្បច្ច័យ មានវារៈ ១២ ក្នុងអវិគតប្បច្ច័យ មានវារៈ ២៣ ។

បញ្ហាវារៈ បណ្ឌិត គប្បីឲ្យពិស្តារផងចុះ ។

# ឧបាទិន្នុបាទានិយត្តិកៈ
# នឧបាទិន្នុបាទានិយត្តិកៈ

[៤០] ធម៌ ដែលមិនមែនកម្មប្រកបដោយកិលេស (មានតណ្ហា ជាដើម) កាន់យកហើយទាំងជាប្រយោជន៍ដល់ឧបាទាន អាស្រ័យ នូវ ធម៌ ដែលកម្មប្រកបដោយកិលេស (មានតណ្ហាជាដើម) កាន់យកហើយ ទាំងជាប្រយោជន៍ដល់ឧបាទាន ទើបកើតឡើង ព្រោះហេតុប្បច្ច័យ

ឧចាជិន្នុចាជាជិយំ ជម្មំ បដិច្ច នអនុចាជិន្នុចាជាជិយោ ជម្មោ ឧប្បជ្ជតិ ហេតុប្បច្ចយា ឧចាជិន្នុចាជាជិយំ ជម្មំ បដិច្ច នអនុចាជិន្នអនុចាជាជិយោ ជម្មោ ឧប្ប-ជ្ជតិ ហេតុប្បច្ចយា ឧចាជិន្នុចាជាជិយំ ជម្មំ បដិច្ច នឧចាជិន្នុចាជាជិយោ ច នអនុចាជិន្នអនុចាជាជិយោ ច ជម្មា ឧប្បជ្ជន្តិ ហេតុប្បច្ចយា ឧចាជិន្នុចាជាជិយំ ជម្មំ បដិច្ច នអនុចាជិន្នុចាជាជិយោ ច នអនុចាជិន្នអ-នុចាជាជិយោ ច ជម្មា ឧប្បជ្ជន្តិ ហេតុប្បច្ចយា បញ្ច ។

ធម៌ ដែលមិនមែនមានកម្មប្រកបដោយកិលេស មិនកាន់យកហើយ តែជាប្រយោជន៍ដល់ឧបាទាន អាស្រ័យ នូវធម៌ ដែលមានកម្មប្រកបដោយកិលេសកាន់យកហើយទាំងជាប្រយោជន៍ដល់ឧបាទាន ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ធម៌ ដែលមិនមែនមានកម្មប្រកបដោយកិលេស មិនកាន់យកហើយទាំងមិនជាប្រយោជន៍ដល់ឧបាទាន អាស្រ័យ នូវធម៌ ដែលមានកម្មប្រកបដោយកិលេសកាន់យកហើយទាំងជាប្រយោជន៍ដល់ឧបាទាន ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ធម៌ ដែលមិនមែនមានកម្មប្រកបដោយកិលេសកាន់យកហើយទាំងជាប្រយោជន៍ដល់ឧបាទានក្តី ដែលមិនមែនមានកម្មប្រកបដោយកិលេសមិនកាន់យកហើយទាំងមិនជាប្រយោជន៍ដល់ឧបាទានក្តី អាស្រ័យ នូវធម៌ ដែលមានកម្មប្រកបដោយកិលេសកាន់យកហើយទាំងជាប្រយោជន៍ដល់ឧបាទាន ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ធម៌ ដែលមិនមែនមានកម្មប្រកបដោយកិលេសកាន់យកហើយតែជាប្រយោជន៍ដល់ឧបាទានក្តី ដែលមិនមែនមានកម្មប្រកបដោយកិលេសមិនកាន់យកហើយទាំងមិនជាប្រយោជន៍ដល់ឧបាទានក្តី អាស្រ័យ នូវធម៌ ដែលមានកម្មប្រកបដោយកិលេសកាន់យកហើយទាំងជាប្រយោជន៍ដល់ឧបាទាន ទើបកើតឡើង ព្រោះហេតុប្បច្ច័យ មានវារៈ ៥ ។

២១

អនុលោមបច្ចនីយត្តិកបដ្ឋានំ

[៤១] អនុបាទិន្នុបាទានិយំ ធម្មំ បដិច្ច នអនុបាទិន្នុបាទានិយោ ធម្មោ ឧប្បជ្ជតិ ហេតុប្បច្ចយា អនុបាទិន្នុបាទានិយំ ធម្មំ បដិច្ច នអនុបាទិន្នអនុបាទានិយោ ធម្មោ ឧប្បជ្ជតិ ហេតុប្បច្ចយា អនុបាទិន្នុបាទានិយំ ធម្មំ បដិច្ច នអនុបាទិន្នុបាទានិយោ ច នអនុបាទិន្នអនុបាទានិយោ ច ធម្មា ឧប្បជ្ជន្តិ ហេតុប្បច្ចយា តីណិ ។

[៤២] អនុបាទិន្នអនុបាទានិយំ ធម្មំ បដិច្ច នអនុបាទិន្នអនុបាទានិយោ ធម្មោ ឧប្បជ្ជតិ ហេតុប្បច្ចយា អនុបាទិន្នអនុបាទានិយំ ធម្មំ បដិច្ច នឧបាទិន្នុបាទានិយោ ធម្មោ ឧប្បជ្ជតិ

អនុលោមប្បច្ចនីយត្តិកប្បដ្ឋាន

[៤១] ធម៌ ដែលមិនមែនមានកម្មប្រកបដោយកិលេសមិនកាន់យកហើយតែជាប្រយោជន៍ដល់ឧបាទាន អាស្រ័យ នូវធម៌ ដែលមានកម្មប្រកបដោយកិលេសមិនកាន់យកហើយតែជាប្រយោជន៍ដល់ឧបាទាន ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ធម៌ ដែលមិនមែនមានកម្មប្រកបដោយកិលេសមិនកាន់យកហើយទាំងមិនជាប្រយោជន៍ដល់ឧបាទាន អាស្រ័យ នូវធម៌ ដែលមានកម្មប្រកបដោយកិលេសមិនកាន់យកហើយតែជាប្រយោជន៍ដល់ឧបាទាន ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ធម៌ ដែលមិនមែនមានកម្មប្រកបដោយកិលេសមិនកាន់យកហើយ តែជាប្រយោជន៍ដល់ឧបាទានក្តី ធម៌ ដែលមិនមែនមានកម្មប្រកបដោយកិលេសមិនកាន់យកហើយទាំងមិនជាប្រយោជន៍ដល់ឧបាទានក្តី អាស្រ័យ នូវធម៌ ដែលមានកម្មប្រកបដោយកិលេសមិនកាន់យកហើយតែជាប្រយោជន៍ដល់ឧបាទាន ទើបកើតឡើង ព្រោះហេតុប្បច្ច័យ មានវារៈ ៣ ។

[៤២] ធម៌ ដែលមិនមែនមានកម្មប្រកបដោយកិលេសមិនកាន់យកហើយទាំងមិនជាប្រយោជន៍ដល់ឧបាទាន អាស្រ័យ នូវធម៌ ដែលមានកម្មប្រកបដោយកិលេសមិនកាន់យកហើយទាំងមិនជាប្រយោជន៍ដល់ឧបាទាន ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ធម៌ ដែលមិនមែនមានកម្មប្រកបដោយកិលេសកាន់យកហើយតែជាប្រយោជន៍ដល់ឧបាទាន អាស្រ័យ នូវធម៌ ដែលមានកម្មប្រកបដោយកិលេសមិនកាន់យកហើយទាំងមិនជាប្រយោជន៍ដល់ឧបាទាន ទើបកើតឡើង

២២



ហេតុប្បច្ចយា អនុបាទិន្នអនុបាទានិយំ ធម្មំ បដិច្ច នអនុបាទិន្នុបាទានិយោ ធម្មោ ឧប្បជ្ជតិ ហេតុប្បច្ចយា អនុបាទិន្នអនុបាទានិយំ ធម្មំ បដិច្ច នឧបាទិន្នុបាទានិយោ ច នអនុបាទិន្នអនុបាទានិយោ ច ធម្មា ឧប្បជ្ជន្តិ ហេតុប្បច្ចយា អនុបាទិន្នអនុបាទានិយំ ធម្មំ បដិច្ច នឧបាទិន្នុបាទានិយោ ច នអនុបាទិន្នុបាទានិយោ ច ធម្មា ឧប្បជ្ជន្តិ ហេតុប្បច្ចយា បញ្ច ។

[៤៣] អនុបាទិន្នុបាទានិយញ្ច អនុបាទិន្នអនុបាទានិយញ្ច ធម្មំ បដិច្ច នឧបាទិន្នុបាទានិយោ ធម្មោ ឧប្បជ្ជតិ ហេតុប្បច្ចយា

ព្រោះហេតុប្បច្ច័យ ធម៌ ដែលមិនមែនមានកម្មប្រកបដោយកិលេស មិនកាន់យកហើយតែជាប្រយោជន៍ដល់ឧបាទាន អាស្រ័យ នូវធម៌ ដែលមានកម្មប្រកបដោយកិលេសមិនកាន់យកហើយ ទាំងជាប្រយោជន៍ដល់ឧបាទាន ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ធម៌ ដែលមិនមែនមានកម្មប្រកបដោយកិលេសកាន់យកហើយ តែជាប្រយោជន៍ដល់ឧបាទានក្តី ដែលមិនមែនមានកម្មប្រកបដោយកិលេសមិនកាន់យកហើយទាំងមិនជាប្រយោជន៍ដល់ឧបាទានក្តី អាស្រ័យ នូវធម៌ ដែលមានកម្មប្រកបដោយកិលេសមិនកាន់យកហើយ ទាំងមិនជាប្រយោជន៍ដល់ឧបាទាន ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ធម៌ ដែលមិនមានកម្មប្រកបដោយកិលេសកាន់យកហើយតែជាប្រយោជន៍ដល់ឧបាទានក្តី ដែលមិនមែនមានកម្មប្រកបដោយកិលេសមិនកាន់យកហើយ តែជាប្រយោជន៍ដល់ឧបាទានក្តី អាស្រ័យ នូវធម៌ ដែលមានកម្មប្រកបដោយកិលេសមិនកាន់យកហើយទាំងមិនជាប្រយោជន៍ដល់ឧបាទាន ទើបកើតឡើង ព្រោះហេតុប្បច្ច័យ មានវារៈ ៩ ។

[៤៣] ធម៌ ដែលមិនមែនមានកម្មប្រកបដោយកិលេសកាន់យកហើយតែជាប្រយោជន៍ដល់ឧបាទាន អាស្រ័យ នូវធម៌ ដែលមានកម្មប្រកបដោយកិលេសមិនកាន់យកហើយ តែជាប្រយោជន៍ដល់ឧបា-ទានផង ដែលមានកម្មប្រកបដោយកិលេសមិនកាន់យកហើយទាំងមិនជាប្រយោជន៍ដល់ឧបាទានផង ទើបកើតឡើង ព្រោះហេតុប្បច្ច័យ

## អនុលោមប្បច្ចនីយត្តិកប្បដ្ឋានំ

អនុបាទិន្នុបាទានិយញ្ច អនុបាទិន្នអនុបាទានិយញ្ច ធម្មំ បដិច្ច នអនុបាទិន្នអនុបាទានិយោ ធម្មោ ឧប្ប-ជ្ជតិ ហេតុប្បច្ចយា អនុបាទិន្នុបាទានិយញ្ច អនុបា-ទិន្នអនុបាទានិយញ្ច ធម្មំ បដិច្ច នឧបាទិន្នុបាទានិ-យោ ច នអនុបាទិន្នអនុបាទានិយោ ច ធម្មា ឧប្ប-ជ្ជន្តិ ហេតុប្បច្ចយា តីណិ ។

[៤៤] ឧបាទិន្នុបាទានិយញ្ច អនុបាទិន្នុបា-ទានិយញ្ច ធម្មំ បដិច្ច នឧបាទិន្នុបាទានិយោ ធម្មោ ឧប្បជ្ជតិ ហេតុប្បច្ចយា ឧបាទិន្នុបាទា-និយញ្ច អនុបាទិន្នុបាទានិយញ្ច ធម្មំ បដិច្ច

ធម៌ ដែលមិនមែនមានកម្មប្រកបដោយកិលេសមិនកាន់យកហើយទាំងមិន ជាប្រយោជន៍ដល់ឧបាទាន អាស្រ័យ នូវធម៌ ដែលមានកម្មប្រកបដោយ កិលេសមិនកាន់យកហើយតែជាប្រយោជន៍ដល់ឧបាទានផង ដែលមាន កម្មប្រកបដោយកិលេសមិនកាន់យកហើយទាំងមិនជាប្រយោជន៍ ដល់ឧបា-ទានផង ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ធម៌ ដែលមិនមានកម្មប្រកប ដោយកិលេសកាន់យកហើយតែជាប្រយោជន៍ដល់ឧបាទានក្តី ដែលមិន មែនមានកម្មប្រកបដោយកិលេសមិនកាន់យកហើយទាំងមិនជាប្រយោជន៍ ដល់ឧបាទានក្តី អាស្រ័យ នូវធម៌ ដែលមានកម្មប្រកបដោយកិលេស មិនកាន់យកហើយតែជាប្រយោជន៍ដល់ឧបាទានផង ដែលមានកម្មប្រកប ដោយកិលេសមិនកាន់យកហើយទាំងមិនជាប្រយោជន៍ដល់ឧបាទានផង ទើបកើតឡើង ព្រោះហេតុប្បច្ច័យ មានវារៈ ៣ ។

[៤៤] ធម៌ ដែលមិនមែនមានកម្មប្រកបដោយកិលេសកាន់យក ហើយតែជាប្រយោជន៍ដល់ឧបាទាន អាស្រ័យ នូវធម៌ ដែលមានកម្ម ប្រកបដោយកិលេសកាន់យកហើយទាំងជាប្រយោជន៍ដល់ឧបាទានផង ដែលមានកម្មប្រកបដោយកិលេសមិនកាន់យកហើយតែជាប្រយោជន៍ ដល់ឧបាទានផង ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ធម៌ ដែល មិនមែនមានកម្មប្រកបដោយកិលេសមិនកាន់យកហើយទាំងមិនជាប្រ-យោជន៍ ដល់ឧបាទាន អាស្រ័យ នូវធម៌ ដែលមានកម្មប្រកបដោយ កិលេសកាន់យកហើយទាំងជាប្រយោជន៍ដល់ឧបាទានផង ដែលមានកម្ម ប្រកបដោយកិលេសមិនកាន់យកហើយតែជាប្រយោជន៍ដល់ឧបាទានផង

នអនុបាទិន្នអនុបាទានិយោ ធម្មោ ឧប្បជ្ជតិ ហេតុប្បច្ចយា ឧបាទិន្នុបាទានិយញ្ច អនុបាទិន្នុបាទានិយញ្ច ធម្មំ បដិច្ច នឧបាទិន្នុបាទានិយោ ច នអនុបាទិន្នអនុបាទានិយោ ច ធម្មា ឧប្បជ្ជន្តិ ហេតុប្បច្ចយា តីណិ ។

[៤៥] ហេតុយា ឯកូនវីស អារម្មណេ នវ អធិបតិយា ឯកាទស សហជាតេ ឯកូនវីស ។ បេ ។

សហជាត . . . បច្ចយ . . . និស្សយ . . . សំសដ្ឋ . . . សម្បយុត្តវារម្បិ វិត្ថារេតព្វំ ។

[៤៦] ឧបាទិន្នុបាទានិយោ ធម្មោ នឧបាទិន្នុបាទានិយស្ស ធម្មស្ស ហេតុប្បច្ចយេន បច្ចយោ ឧបាទិន្នុបាទានិយោ ធម្មោ នអនុបាទិន្នុបាទានិយស្ស ធម្មស្ស ហេតុប្បច្ចយេន បច្ចយោ ។ បេ ។

ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ធម៌ ដែលមិនមែនមានកម្មប្រកប ដោយកិលេសកាន់យកហើយ ទាំងជាប្រយោជន៍ដល់ឧបាទានក្តី ធម៌ ដែលមិនមែនមានកម្មប្រកបដោយកិលេសមិនកាន់យកហើយទាំងមិនជា ប្រយោជន៍ដល់ឧបាទានក្តី អាស្រ័យ នូវធម៌ ដែលមានកម្មប្រកបដោយ កិលេសកាន់យកហើយទាំងជាប្រយោជន៍ដល់ឧបាទានផង ដែលមានកម្ម ប្រកបដោយកិលេសមិនកាន់យកហើយតែជាប្រយោជន៍ដល់ឧបាទានផង ទើបកើតឡើង ព្រោះហេតុប្បច្ច័យ មានវារៈ ៣ ។

[៤៥] ក្នុងហេតុប្បច្ច័យ មានវារៈ ១៩ ក្នុងអារម្មណប្បច្ច័យ មានវារៈ ៩ ក្នុងអធិបតិប្បច្ច័យ មានវារៈ ១១ ក្នុងសហជាតប្បច្ច័យ មានវារៈ ១៩ ។ បេ ។

សហជាត . . . បច្ចយ . . . និស្សយ . . . សំសដ្ឋ . . . និងសម្ប-យុត្តវារៈ បណ្ឌិត គប្បីឲ្យពិស្តារផងចុះ ។

[៤៦] ធម៌ ដែលមានកម្មប្រកបដោយកិលេសកាន់យកហើយ ទាំងជាប្រយោជន៍ដល់ឧបាទាន ជាបច្ច័យ នៃធម៌ ដែលមិនមែនមាន កម្មប្រកបដោយកិលេសកាន់យកហើយទាំងជាប្រយោជន៍ដល់ឧបាទាន ដោយហេតុប្បច្ច័យ ធម៌ ដែលមានកម្មប្រកបដោយកិលេសកាន់យក ហើយទាំងជាប្រយោជន៍ដល់ឧបាទាន ជាបច្ច័យ នៃធម៌ ដែលមិន មែនមានកម្មប្រកបដោយកិលេសមិនកាន់យកហើយតែជាប្រយោជន៍ដល់ ឧបាទាន ដោយហេតុប្បច្ច័យ ។ បេ ។

អនុលោមបច្ចនីយត្តិកប្បដ្ឋានំ

[៤៧] ឧបាទិន្នុបាទានិយោ ធម្មោ នឧបាទិន្នុ-
បាទានិយស្ស ធម្មស្ស អារម្មណប្បច្ចយេន បច្ចយោ
ឧបាទិន្នុបាទានិយោ ធម្មោ នអនុបាទិន្នុបាទានិយស្ស
ធម្មស្ស អារម្មណប្បច្ចយេន បច្ចយោ ឧបាទិន្នុបាទា-
និយោ ធម្មោ នអនុបាទិន្នអនុបាទានិយស្ស ធម្មស្ស
អារម្មណប្បច្ចយេន បច្ចយោ ឧបាទិន្នុបាទានិយោ
ធម្មោ នឧបាទិន្នុបាទានិយស្ស ច នអនុបាទិន្នអនុ-
បាទានិយស្ស ច ធម្មស្ស អារម្មណប្បច្ចយេន បច្ចយោ
ឧបាទិន្នុបាទានិយោ ធម្មោ នអនុបាទិន្នុបាទានិយស្ស
ច នអនុបាទិន្នអនុបាទានិយស្ស ច ធម្មស្ស អារម្ម-
ណប្បច្ចយេន បច្ចយោ បញ្ច ។

អនុលោមប្បច្ចនីយត្តិកប្បដ្ឋាន

[៤៧] ធម៌ ដែលមានកម្មប្រកបដោយកិលេស កាន់យកហើយទាំងជាប្រយោជន៍ដល់ឧបាទាន ជាបច្ច័យ នៃធម៌ ដែលមិនមែនមានកម្មប្រកបដោយកិលេសកាន់យកហើយទាំងជាប្រយោជន៍ដល់ឧបាទាន ដោយអារម្មណប្បច្ច័យ ធម៌ ដែលមានកម្មប្រកបដោយកិលេសកាន់យកហើយទាំងជាប្រយោជន៍ដល់ឧបាទាន ជាបច្ច័យ នៃធម៌ ដែលមិនមែនមានកម្មប្រកបដោយកិលេស មិនកាន់យកហើយតែជាប្រយោជន៍ដល់ឧ-បាទាន ដោយអារម្មណប្បច្ច័យ ធម៌ ដែលមានកម្មប្រកបដោយកិ-លេសកាន់យកហើយទាំងជាប្រយោជន៍ដល់ឧបាទាន ជាបច្ច័យ នៃធម៌ ដែលមិនមែនមានកម្មប្រកបដោយកិលេស មិនកាន់យកហើយទាំងមិនជាប្រយោជន៍ដល់ឧបាទាន ដោយអារម្មណប្បច្ច័យ ធម៌ ដែលមានកម្មប្រកបដោយកិលេសកាន់យកហើយទាំងជាប្រយោជន៍ ដល់ឧបា-ទាន ជាបច្ច័យ នៃធម៌ ដែលមិនមែនមានកម្មប្រកបដោយកិលេសកាន់យកហើយទាំងជាប្រយោជន៍ដល់ឧបាទានផង ដែលមិនមែនមានកម្មប្រកបដោយកិលេសមិនកាន់យកហើយ ទាំងមិនជាប្រយោជន៍ដល់ឧបា-ទានផង ដោយអារម្មណប្បច្ច័យ ធម៌ ដែលមានកម្មប្រកបដោយកិលេសកាន់យកហើយទាំងជាប្រយោជន៍ដល់ឧបាទាន ជាបច្ច័យ នៃធម៌ ដែលមិនមែនមានកម្មប្រកបដោយកិលេសមិនកាន់យកហើយតែជាប្រយោជន៍ដល់ឧបាទានផង ដែលមិនមែនមានកម្មប្រកបដោយកិ-លេសមិនកាន់យកហើយទាំងមិនជាប្រយោជន៍ដល់ឧបាទានផង ដោយអារម្មណប្បច្ច័យ មានវារៈ ៥ ។

[៤៨] អនុបាទិន្នុបាទានិយោ ធម្មោ នអនុបា-
ទិន្នុបាទានិយស្ស ធម្មស្ស អារម្មណប្បច្ចយេន បច្ច-
យោ អនុបាទិន្នុបាទានិយោ ធម្មោ នឧបាទិន្នុបាទានិ-
យស្ស ធម្មស្ស អារម្មណប្បច្ចយេន បច្ចយោ អនុបា-
ទិន្នុបាទានិយោ ធម្មោ នអនុបាទិន្នអនុបាទានិយស្ស
ធម្មស្ស អារម្មណប្បច្ចយេន បច្ចយោ អនុបាទិន្នុបាទា-
និយោ ធម្មោ នឧបាទិន្នុបាទានិយស្ស ច នអនុបា-
ទិន្នអនុបាទានិយស្ស ច ធម្មស្ស អារម្មណប្បច្ច-
យេន បច្ចយោ អនុបាទិន្នុបាទានិយោ ធម្មោ នអនុ-
បាទិន្នុបាទានិយស្ស ច នអនុបាទិន្នអនុបាទានិយស្ស
ច ធម្មស្ស អារម្មណប្បច្ចយេន បច្ចយោ បញ្ច ។

[៤៨] ធម៌ ដែលមានកម្មប្រកបដោយកិលេស មិនកាន់យកហើយតែជាប្រយោជន៍ដល់ឧបាទាន ជាបច្ច័យ នៃធម៌ ដែលមិនមែនមានកម្មប្រកបដោយកិលេសមិនកាន់យកហើយតែជាប្រយោជន៍ដល់ឧបា-ទាន ដោយអារម្មណប្បច្ច័យ ធម៌ ដែលមានកម្មប្រកបដោយកិលេសមិនកាន់យកហើយតែជាប្រយោជន៍ដល់ឧបាទាន ជាបច្ច័យនៃធម៌ ដែលមិនមែនមានកម្មប្រកបដោយកិលេសកាន់យកហើយទាំងជាប្រយោជន៍ដល់ឧបាទាន ដោយអារម្មណប្បច្ច័យ ធម៌ ដែលមានកម្មប្រកបដោយកិលេសមិនកាន់យកហើយតែជាប្រយោជន៍ដល់ឧបាទាន ជាបច្ច័យ នៃធម៌ដែលមិនមែនមានកម្មប្រកបដោយកិលេសមិនកាន់យកហើយទាំងមិនជាប្រយោជន៍ដល់ឧបាទាន ដោយអារម្មណប្បច្ច័យ ធម៌ ដែលមានកម្មប្រកបដោយកិលេសមិនកាន់យកហើយតែជាប្រយោជន៍ដល់ឧបាទាន ជាបច្ច័យ នៃធម៌ ដែលមិនមែនមានកម្មប្រកបដោយកិលេសកាន់យកហើយទាំងជាប្រយោជន៍ដល់ឧបាទានផង ដែលមិនមែនមានកម្មប្រកបដោយកិលេសមិនកាន់យកហើយទាំងមិនជាប្រយោជន៍ដល់ឧបាទានផង ដោយអារម្មណប្បច្ច័យ ធម៌ ដែលមានកម្មប្រកបដោយកិលេសមិនកាន់យកហើយតែជាប្រយោជន៍ដល់ឧបាទាន ជាបច្ច័យ នៃធម៌ ដែលមិនមែនមានកម្មប្រកបដោយកិលេសមិនកាន់យកហើយតែជាប្រយោជន៍ដល់ឧបាទានផង ដែលមិនមែនមានកម្មប្រកបដោយកិលេសមិនកាន់យកហើយទាំងមិនជាប្រយោជន៍ដល់ឧបាទានផង ដោយអារម្មណប្បច្ច័យ មានវារៈ ៥ ។

២៧

អនុលោមប្បច្ចនីយត្តិកប្បដ្ឋានំ

[៤៩] អនុចាជិន្នអនុចាធានិយោ ធម្មោ នអនុ-ចាជិន្នអនុចាធានិយស្ស ធម្មស្ស អារម្មណាប្បច្ចយេន បច្ចយោ ។ បេ ។ បញ្ហ ។

[៥០] ហេតុយា តេរស អារម្មណេ បណ្ណរស អធិបតិយា ឯកាទស ។ បេ ។

បញ្ហាវារម្បិ វិត្ថារេតព្វំ ។

# សង្កិលិដ្ឋសង្កិលេសិកត្តិកេ

# នសង្កិលិដ្ឋសង្កិលេសិកត្តិកំ

[៥១] សង្កិលិដ្ឋសង្កិលេសិកំ ធម្មំ បដិច្ច ន-សង្កិលិដ្ឋសង្កិលេសិកោ ធម្មោ ឧប្បជ្ជតិ ហេតុប្បច្-យា សង្កិលិដ្ឋសង្កិលេសិកំ ធម្មំ បដិច្ច នអសង្កិ-លិដ្ឋសង្កិលេសិកោ ធម្មោ ឧប្បជ្ជតិ ហេតុប្បច្ចយា សង្កិលិដ្ឋសង្កិលេសិកំ ធម្មំ បដិច្ច នអសង្កិលិដ្ឋ-អសង្កិលេសិកោ ធម្មោ ឧប្បជ្ជតិ ហេតុប្បច្ចយា

អនុលោមបច្ចនីយបដ្ឋាន

[៤៩] ធម៌ ដែលមានកម្មប្រកបដោយកិលេសមិនកាន់យកហើយទាំងមិនជាប្រយោជន៍ដល់ឧបាទាន ជាបច្ច័យ នៃធម៌ ដែលមិនមែនមានកម្មប្រកបដោយកិលេសមិនកាន់យកហើយទាំងមិនជាប្រយោជន៍ដល់ឧបាទាន ដោយអារម្មណបច្ច័យ ។ បេ ។ មានវារៈ ៥ ។

[៥០] ក្នុងហេតុបច្ច័យ មានវារៈ ១៣ ក្នុងអារម្មណបច្ច័យ មានវារៈ ១៥ ក្នុងអធិបតិបច្ច័យ មានវារៈ ១១ ។ បេ ។

បញ្ហាវារៈ បណ្ឌិត គប្បីឲ្យពិស្ដារផងចុះ ។

# សង្កិលិដ្ឋសង្កិលេសិកត្តិកៈ

# នសង្កិលិដ្ឋសង្កិលេសិកត្តិកៈ

[៥១] ធម៌ ដែលមិនសៅហ្មងទាំងគួរដល់សេចក្ដីសៅហ្មង អាស្រ័យ នូវធម៌ ដែលសៅហ្មងទាំងគួរដល់សេចក្ដីសៅហ្មង ទើបកើតឡើង ព្រោះហេតុបច្ច័យ ធម៌ ដែលមិនមែនជាមិនសៅហ្មងតែគួរដល់សេចក្ដីសៅហ្មង អាស្រ័យ នូវធម៌ ដែលសៅហ្មងទាំងគួរដល់សេចក្ដីសៅហ្មង ទើបកើតឡើង ព្រោះហេតុបច្ច័យ ធម៌ ដែលមិនមែនជាមិនសៅហ្មងទាំងមិនគួរដល់សេចក្ដីសៅហ្មង អាស្រ័យ នូវធម៌ ដែលសៅហ្មងទាំងគួរដល់សេចក្ដីសៅហ្មង ទើបកើតឡើង ព្រោះហេតុបច្ច័យ

សង្កិលិដ្ឋសង្កិលេសិកំ ធម្មំ បដិច្ច នសង្កិលិដ្ឋស-
ង្កិលេសិកោ ច នអសង្កិលិដ្ឋអសង្កិលេសិកោ ច
ធម្មា ឧប្បជ្ជន្តិ ហេតុប្បច្ចយា សង្កិលិដ្ឋសង្កិលេសិកំ
ធម្មំ បដិច្ច នអសង្កិលិដ្ឋសង្កិលេសិកោ ច នអសង្កិ-
លិដ្ឋអសង្កិលេសិកោ ច ធម្មា ឧប្បជ្ជន្តិ ហេតុប្បច្ច-
យា បញ្ច ។

[៤២] អសង្កិលិដ្ឋសង្កិលេសិកំ ធម្មំ បដិច្ច ន-
សង្កិលិដ្ឋសង្កិលេសិកោ ធម្មោ ឧប្បជ្ជតិ ហេតុប្បច្ចយា
អសង្កិលិដ្ឋសង្កិលេសិកំ ធម្មំ បដិច្ច នអសង្កិលិដ្ឋ-
អសង្កិលេសិកោ ធម្មោ ឧប្បជ្ជតិ ហេតុប្បច្ចយា អ-
សង្កិលិដ្ឋសង្កិលេសិកំ ធម្មំ បដិច្ច នសង្កិលិដ្ឋសង្កិ-
លេសិកោ ច នអសង្កិលិដ្ឋអសង្កិលេសិកោ ច
ធម្មា ឧប្បជ្ជន្តិ ហេតុប្បច្ចយា តីណិ ។

[៤៣] អសង្កិលិដ្ឋអសង្កិលេសិកំ ធម្មំ
បដិច្ច នអសង្កិលិដ្ឋអសង្កិលេសិកោ ធម្មោ

ធម៌ ដែលមិនមែនសោហ្មង់តែគួរដល់សេចក្ដីសោហ្មង់ក្ដី ធម៌ ដែលមិនមែនជាមិនសោហ្មង់ទាំងមិនគួរដល់សេចក្ដីសោហ្មង់ក្ដី អាស្រ័យ នូវធម៌ ដែលសោហ្មង់ទាំងគួរដល់សេចក្ដីសោហ្មង់ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ធម៌ ដែលមិនមែនជាមិនសោហ្មង់តែគួរដល់សេចក្ដីសោ-ហ្មង់ក្ដី ធម៌ ដែលមិនមែនជាមិនសោហ្មង់ទាំងមិនគួរដល់សេចក្ដីសោហ្មង់ក្ដី អាស្រ័យ នូវធម៌ ដែលសោហ្មង់ទាំងគួរដល់សេចក្ដីសោហ្មង់ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ មានវារៈ ៥ ។

[៥២] ធម៌ ដែលមិនសោហ្មង់តែគួរដល់សេចក្ដីសោហ្មង់ អា-ស្រ័យ នូវធម៌ ដែលមិនសោហ្មង់តែគួរដល់សេចក្ដីសោហ្មង់ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ធម៌ ដែលមិនមែនជាមិនសោហ្មង់ទាំងមិនគួរដល់សេចក្ដីសោហ្មង់ អាស្រ័យ នូវធម៌ ដែលមិនសោហ្មង់តែគួរដល់សេចក្ដីសោហ្មង់ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ធម៌ ដែលមិនមែនសោហ្មង់តែគួរដល់សេចក្ដីសោហ្មង់ក្ដី ធម៌ ដែលមិនមែនជាមិនសោហ្មង់ទាំងមិនគួរដល់សេចក្ដីសោហ្មង់ក្ដី អាស្រ័យ នូវធម៌ ដែលមិនសោហ្មង់តែគួរដល់សេចក្ដីសោហ្មង់ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ មានវារៈ ៣ ។

[៥៣] ធម៌ ដែលមិនមែនជាមិនសោហ្មង់ទាំងមិនគួរដល់សេចក្ដីសោ-ហ្មង់ អាស្រ័យ នូវធម៌ ដែលមិនសោហ្មង់ទាំងមិនគួរដល់សេចក្ដីសោហ្មង់

២៩

អនុលោមបច្ចនីយត្តិកបដ្ឋានំ

ឧប្បជ្ជតិ ហេតុប្បច្ចយា អសង្កិលិដ្ឋអសង្កិលេសិកំ ធម្មំ បដិច្ច នសង្កិលិដ្ឋសង្កិលេសិកោ ធម្មោ ឧប្បជ្ជតិ ហេតុប្បច្ចយា អសង្កិលិដ្ឋអសង្កិលេសិកំ ធម្មំ បដិច្ច នអសង្កិលិដ្ឋសង្កិលេសិកោ ធម្មោ ឧប្បជ្ជតិ ហេតុ-ប្បច្ចយា អសង្កិលិដ្ឋអសង្កិលេសិកំ ធម្មំ បដិច្ច ន-សង្កិលិដ្ឋសង្កិលេសិកោ ច នអសង្កិលិដ្ឋអសង្កិលេ-សិកោ ច ធម្មា ឧប្បជ្ជន្តិ ហេតុប្បច្ចយា អសង្កិលិដ្ឋអ-សង្កិលេសិកំ ធម្មំ បដិច្ច នសង្កិលិដ្ឋសង្កិលេសិកោ ច នអសង្កិលិដ្ឋសង្កិលេសិកោ ច ធម្មា ឧប្បជ្ជន្តិ ហេតុប្បច្ចយា បញ្ច ។

[៥៤] សង្កិលិដ្ឋសង្កិលេសិកញ្ច អសង្កិលិដ្ឋអ-សង្កិលេសិកញ្ច ធម្មំ បដិច្ច នអសង្កិលិដ្ឋសង្កិលេ-សិកោ ធម្មោ ឧប្បជ្ជតិ ហេតុប្បច្ចយា តីណិ ។

[៥៥] អសង្កិលិដ្ឋសង្កិលេសិកញ្ច អសង្កិលិដ្ឋ-អសង្កិលេសិកញ្ច ធម្មំ បដិច្ច នអសង្កិលិដ្ឋសង្កិលេ-សិកោ ធម្មោ ឧប្បជ្ជតិ ហេតុប្បច្ចយា ។ បេ ។ តីណិ ។

ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ធម៌ ដែលមិនមែនសោហ្មង់តែគួរដល់សេចក្ដីសៅហ្មង អាស្រ័យ នូវធម៌ ដែលមិនសៅហ្មង់ទាំងមិនគួរដល់សេចក្ដីសៅហ្មង ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ធម៌ ដែលមិនមែនជាមិនសៅហ្មង់តែគួរដល់សេចក្ដីសៅហ្មង អាស្រ័យ នូវធម៌ ដែលមិនសៅហ្មង់ទាំងមិនគួរដល់សេចក្ដីសៅហ្មង ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ធម៌ ដែលមិនសៅហ្មង់តែគួរដល់សេចក្ដីសៅហ្មង់ក្ដី ធម៌ ដែលមិនមែនជាមិនសៅហ្មង់ទាំងមិនគួរដល់សេចក្ដីសៅហ្មង់ក្ដី អាស្រ័យ នូវធម៌ ដែលមិនសៅហ្មង់ទាំងមិនគួរដល់សេចក្ដីសៅហ្មង ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ធម៌ ដែលមិនមែនសៅហ្មង់តែគួរដល់សេចក្ដីសៅហ្មង់ក្ដី ធម៌ ដែលមិនមែនជាមិនសៅហ្មង់តែគួរដល់សេចក្ដីសៅហ្មង់ក្ដី អាស្រ័យ នូវធម៌ ដែលមិនសៅហ្មង់ទាំងមិនគួរដល់សេចក្ដីសៅហ្មង ទើបកើតឡើង ព្រោះហេតុប្បច្ច័យ មានវារៈ ៥ ។

[៥៤] ធម៌ ដែលមិនមែនជាមិនសៅហ្មង់តែគួរដល់សេចក្ដីសៅហ្មង អាស្រ័យ នូវធម៌ ដែលសៅហ្មង់ទាំងគួរដល់សេចក្ដីសៅហ្មង់ផង នូវធម៌ ដែលមិនសៅហ្មង់ទាំងមិនគួរដល់សេចក្ដីសៅហ្មង់ផង ទើបកើតឡើង ព្រោះហេតុប្បច្ច័យ មានវារៈ ៣ ។

[៥៥] ធម៌ ដែលមិនមែនជាមិនសៅហ្មង់តែគួរដល់សេចក្ដីសៅហ្មង អាស្រ័យ នូវធម៌ ដែលមិនសៅហ្មង់តែគួរដល់សេចក្ដីសៅហ្មង់ផង នូវធម៌ ដែលមិនសៅហ្មង់ទាំងមិនគួរដល់សេចក្ដីសៅហ្មង់ផង ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។ បេ ។ មានវារៈ ៣ ។

[៤៦] ហេតុយា ឯកាទស អារម្មណេ ទស អវិ-
គតេ ឯកាទស ។ បេ ។

សហជាតវារម្បិ បច្ចយ ... និស្សយ ... សំសដ្ឋ
...សម្បយុត្តវារម្បិ បញ្ហាវារេ សទិសំ ។

[៤៧] ហេតុយា តេរស អារម្មណេ បណ្ណរស
អធិបតិយា បណ្ណរស អនន្តរេ សោឡស ។ បេ ។
បុរេជាតេ ច បច្ឆាជាតេ ទស អាសេវនេ អដ្ឋ កម្មេ
តេរស វិបាកេ អដ្ឋ អាហារេ តេរស ។ បេ ។
វិប្បយុត្តេ ទ្វាទស អវិគតេ ចព្វីស ។

# វិតក្កត្តិកេ នវិតក្កត្តិកំ

[៤៨] សវិតក្កសវិចារំ ធម្មំ បដិច្ច នសវិតក្កសវិចា-
រោ ធម្មោ ឧប្បជ្ជតិ ហេតុប្បច្ចយា សវិតក្កសវិចារំ ធម្មំ
បដិច្ច នអវិតក្កវិចារមត្តោ ធម្មោ ឧប្បជ្ជតិ ហេតុប្បច្ចយា
សវិតក្កសវិចារំ ធម្មំ បដិច្ច នអវិតក្កអវិចារោ ធម្មោ

[៥៦] ក្នុងហេតុប្បច្ច័យ មានវារៈ ១៩ ក្នុងអារម្មណប្បច្ច័យ មានវារៈ ៩ ក្នុងអវិគតប្បច្ច័យ មានវារៈ ១៩ ។ បេ ។

សហជាតវារៈក្តី បច្ចយ . . . និស្សយ . . . សំសដ្ឋ . . .

សម្បយុត្តវារៈក្តី ប្រហែលគ្នានឹងបញ្ហាវារៈដែរ ។

